# ក្រសួងអភិវឌ្ឍន៍ជនបទ

## ផែនការយុទ្ធសាស្ត្រ
## ថវិកាឆ្នាំ ២០២៣-២០២៥

### កម្មវិធី

១.អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍

២.កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

៣.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

៤.ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ

**លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទ**
**ប្រកបដោយបរិយាប័ន្នទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌**

ថ្ងៃព្រហស្បតិ៍ ៩កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២២

# មាតិកា


**១.សេចក្តីផ្តើម** ........................................................ ១

១.១. ចក្ខុវិស័យ ........................................................ ១

១.២.តួនាទី និងបេសកកម្ម ........................................................ ១

១.៣.គោលបំណង និងគោលដៅ ........................................................ ១

**២. លទ្ធផលសម្រេចបាន និងការប្រឈមក្នុង ឆ្នាំ២០២១** ........................................................ ២

២.១.កម្មវិធីទី១.ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ ........................ ៣

២.២.កម្មវិធីទី២.ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ ........................ ៧

២.៣. កម្មវិធីទី៣៖ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ ........................ ១២

២.៤.កម្មវិធីទី៤៖ ពង្រឹងសេវាគាំទ្ររដ្ឋបាលនិងកិច្ចការទូទៅ ........................ ១៤

២.៥.បញ្ហាប្រឈមសម្រាប់ដោះស្រាយឆ្នាំ២០២២ និងឆ្នាំ២០២៣ ........................ ១៧

**៣. ទិសដៅការគោលនយោបាយអាទិភាព សម្រាប់រួមចំណែកអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាល និងអន្តរវិស័យក្នុងវិស័យអភិវឌ្ឍន៍ជនបទ ឆ្នាំ២០២៣-២០២៥** ......... ១៩

៣.១.ផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ ........................ ២០

៣.២. គោលបំណងគោលនយោបាយ ........................ ២១

៣.៤.ការរៀបចំកម្មវិធី ........................ ២១

**៤. ការកំណត់ធនធាន** ........................ ២២

**៥. សេចក្តីសន្និដ្ឋាន** ........................ ២៣

*ឧបសម្ព័ន ទី១៖ គម្រោងផែនការវិនិយោគសាធារណៈ (PIP) បីឆ្នាំរំកិល ឆ្នាំ២០២៣-២០២៥*

*ឧបសម្ព័ន ទី២៖ បញ្ជីឈ្មោះអ្នកគ្រប់គ្រងគម្រោង*

*ឧបសម្ព័ន្ធ ទី៣៖ កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវ*

*ឧបសម្ព័ន្ធ ទី៤៖ ការកំណត់រចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម*

*ឧបសម្ព័ន្ធ ទី៥៖ ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅនៃកម្មវិធី និងអនុកម្មវិធី*

*ឧបសម្ព័ន្ធ ទី៦៖ ការកំណត់ធនធាន*

# មាតិកា


**១.សេចក្តីផ្តើម** ..................... ១

១.១. ចក្ខុវិស័យ១

១.២.តួនាទី និងបេសកកម្ម ..................... ១

១.៣.គោលបំណង និងគោលដៅ ..................... ១

**២. លទ្ធផលសម្រេចបាន និងការប្រឈមក្នុង ឆ្នាំ២០២១** ..................... ២

២.១.កម្មវិធីទី១.ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍..................... ៣

២.២.កម្មវិធីទី២.ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ ..................... ៧

២.៣. កម្មវិធីទី៣៖ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ..................... ១២

២.៤.កម្មវិធីទី៤៖ ពង្រឹងសេវាគាំទ្ររដ្ឋបាលនិងកិច្ចការទូទៅ ..................... ១៤

២.៥.បញ្ហាប្រឈមសម្រាប់ដោះស្រាយឆ្នាំ២០២២ និងឆ្នាំ២០២៣ ..................... ១៧

**៣. ទិសដៅការគោលនយោបាយអាទិភាព សម្រាប់រួមចំណែកអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាល និងអន្តរវិស័យក្នុងវិស័យអភិវឌ្ឍន៍ជនបទ ឆ្នាំ២០២៣-២០២៥**......... ១៩

៣.១.ផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ ..................... ២០

៣.២. គោលបំណងគោលនយោបាយ ..................... ២១

៣.៤.ការរៀបចំកម្មវិធី ..................... ២១

**៤. ការកំណត់ធនធាន**..................... ២២

**៥. សេចក្តីសន្និដ្ឋាន** ..................... ២៣

*ឧបសម្ព័ន ទី១៖ គម្រោងផែនការវិនិយោគសាធារណៈ (PIP) បីឆ្នាំរំកិល ឆ្នាំ២០២៣-២០២៥*

*ឧបសម្ព័ន ទី២៖ បញ្ជីឈ្មោះអ្នកគ្រប់គ្រងគម្រោង*

*ឧបសម្ព័ន្ធ ទី៣៖ កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវ*

*ឧបសម្ព័ន្ធ ទី៤៖ ការកំណត់រចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម*

*ឧបសម្ព័ន្ធ ទី៥៖ ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅនៃកម្មវិធី និងអនុកម្មវិធី*

*ឧបសម្ព័ន្ធ ទី៦៖ ការកំណត់ធនធាន*

## ១.សេចក្តីផ្តើម

### ១.១. ចក្ខុវិស័យ

ផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២៣-២០២៥ មានចក្ខុវិស័យចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតំបន់ជនបទ និងជំរុញកំណើនសេដ្ឋកិច្ចជនបទឲ្យបានឆាប់រហ័ស ដើម្បីលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាជនជនបទឲ្យបានប្រសើរឡើង។

### ១.២.តួនាទី និងបេសកកម្ម

ផែនការយុទ្ធសាស្ត្រនេះមានបេសកកម្ម លើកបង្កើតការងារ មុខរបរ បង្កើនប្រាក់ចំណូលតាមគ្រួសារ និងបង្កើនសុខុមាលភាពជូនប្រជាជននៅជនបទ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគមនាគមន៍ និងសេវាអប់រំសុខភាព អនាម័យ គាំទ្រដល់សកម្មភាពសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌នៅតាមតំបន់ជនបទ ដើម្បីកែលម្អលក្ខខណ្ឌជីវិតរស់នៅរបស់ប្រជាជនឲ្យមានផាសុខភាព។

### ១.៣.គោលបំណង និងគោលដៅ

ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានតម្រង់គោលដៅស្របគ្នាទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០៣០។

- **គោលបំណង**

ផែនការយុទ្ធសាស្ត្រនេះ មានគោលបំណងពីរ គឺបង្កើនប្រាក់ចំណូលតាមគ្រួសារ និងផ្តល់សេវាសុខភាព អនាម័យនៅជនបទ ពោលគឺប្រែក្លាយតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជាជាតំបន់អភិវឌ្ឍន៍ប្រកបដោយ និរន្តរភាព ដោយមានហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ប្រទាក់ក្រឡាគ្នាប្រកបដោយគុណភាព និងមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋាន ដើម្បីបំណិនជីវិតដើម្បីងាយស្រួលក្នុងការបង្កើតសកម្មភាពសេដ្ឋកិច្ច ផ្តល់សេវាទឹកស្អាត សាងសង់បង្គន់អនាម័យ អប់រំសុខភាព ការសំអាត ដើម្បីគាំទ្រដល់សុខុមាលភាពប្រជាជន។

- **សូចនាករគោលដៅចុងក្រោយ (២០២៣)**

គោលដៅចម្បងនៃផែនការយុទ្ធសាស្ត្រនេះ បង្កើនគុណភាពជីវិតរបស់ប្រជាជនឲ្យបានល្អប្រសើរ គឺសំដៅដល់ជីវភាពសមរម្យ សុខភាពមាំមួន និងបង្កើនគុណតម្លៃនៃជីវិតរបស់ប្រជាជន សំដៅរក្សាភាពថ្លៃថ្នូររបស់សង្គមជនបទ ពោលគឺជាប្រជាជនដែលមានចំណេះវិជ្ជាជាមូលដ្ឋាន និងមានគំនិតច្នៃប្រឌិតបង្កើតថ្មី ដើម្បីបម្រើគ្រួសារ និងសង្គមជាតិ រួមមាន៖

- ស្ថាបនាឲ្យបានផ្លូវជនបទប្រវែងឲ្យបាន ៤៣ ៨១៨ គ.ម និងផ្លូវចាក់កៅស៊ូប្រវែង ៩៩១ គម នៅឆ្នាំ២០២៣
- ថែទាំ ជួសជុល កែលម្អផ្លូវជនបទប្រវែងឲ្យបានប្រវែង ១៨ ៥៥៦ គ.ម
- សម្រេចឲ្យបាននូវគោលដៅរួម ៩០% នៃការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ

ជនបទ នៅឆ្នាំ២០២៣

- ជំរុញខេត្តយ៉ាងតិចចំនួន ០៥ ឈានទៅឈប់បន្ទោរបង់ពាសវាលពាសកាល (ODF)
- បង្កើតមុខរបរ និងការងារឲ្យបាន ៣៥,០០០នាក់ ជូនប្រជាជនជនបទដើម្បីលើកកម្ពស់លក្ខខណ្ឌជីវិតរស់នៅបានល្អប្រសើរ
- បង្កើនការផ្ទេរមុខងារវិមជ្ឈការ និងវិសហមជ្ឈការ ៥០ស្រុក បន្ថែមទៀត
- ជំរុញ និងលើកទឹកចិត្តមន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទឲ្យទទួលបានការបណ្តុះបណ្តាលជំនាញពិសេស ទៅលើបដិវត្តន៍ឧស្សាហកម្ម ៤.០
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានចល័តចំនួន ២៥កន្លែង
- ធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ៥០០ភូមិ
- កំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចឲ្យបាន ២០០សហគមន៍
- បន្តចូលរួមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ និងទី៤ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ២. លទ្ធផលសម្រេចបាន និងការប្រឈមក្នុង ឆ្នាំ២០២១

ក្នុងអាណត្តិរាជរដ្ឋាភិបាលទី៦ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ៥ឆ្នាំ ២០១៩-២០២៣ ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល ក្នុងនោះ ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញជាគោលនយោបាយមួយគឺ **លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទ ប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌** ដោយមានកម្មវិធីចំនួន ៤ ដូចជា (១).ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍, (២).ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ, (៣).ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ និង(៤).ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ។ កម្មវិធីទាំង ៤ ខាងលើត្រូវបានកំណត់សូចនាករមេចំនួន ១១ សម្រាប់តាមដាន វាយតម្លៃ ការអនុវត្តកម្មវិធីផងដែរសម្រាប់ឆ្នាំ២០២១ មានសូចនាករដូចខាងក្រោម៖ (១).ការស្តារ និងសាងសង់ផ្លូវជនបទ (លើប្រវែងផ្លូវសរុប ៤៥ ២០០គ.ម) ឲ្យបាន ៣៦០០៨គ.ម នៅឆ្នាំ២០២១ ពោលគឺសាងសង់ផ្លូវថ្មីសម្រេចឲ្យបាន ៣ ១០១គ.ម ក្នុងឆ្នាំ២០២១, (២).កែលម្អផ្លូវ ជនបទទៅជាកៅស៊ូពីជាន់ ឬបេតុងដើម្បីធន់នឹងការប្រែប្រួលអាកាសធាតុ ១៧២គ.ម នៅឆ្នាំ២០២១, (៣).ថែទាំផ្លូវជាលក្ខណៈខួប និងប្រចាំចំនួន ១២ ៨៨៦គ.ម ពោលគឺជួសជុល ថែទាំផ្លូវ ជនបទគ្រប់ ប្រភេទឲ្យបាន ២ ១៤៨គ.ម ក្នុងឆ្នាំ២០២១, (៤).ភាគរយប្រជាជនជនបទទទួលបានការផ្គត់ផ្គង់ទឹក ដែលមានការកែលម្អប្រកបដោយនិរន្តរភាពឲ្យបានដល់ ៧៨% ក្នុងឆ្នាំ២០២១, (៥).ភាគរយប្រជាជនជនបទទទួលបានសេវាអនាម័យដែលមានការកែលម្អប្រកបដោយនិរន្តរភាពឲ្យបានដល់ ៨៤% ក្នុងឆ្នាំ២០២១, (៦).ខេត្តដែលបានបញ្ឈប់បន្ទោបង់ពាសវាលពាសកាល (ODF) ឲ្យបានដល់៣ខេត្ត ពោលគឺសម្រេចឲ្យបាន ១ខេត្ត ក្នុងឆ្នាំ២០២១, (៧).មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈចល័តឲ្យបានដល់ ១៥ ខេត្ត នៅឆ្នាំ២០២១ ពោលគឺសម្រេចឲ្យបាន ៥ ខេត្ត ក្នុងឆ្នាំ២០២១, (៨).ចំនួនប្រជាពលរដ្ឋដែលបានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋានចំនួន ១៥ ០០០ នាក់, (៩).ចំនួនគ្រួសារ

ដែលបានបង្កើតសហគ្រាសខ្នាតតូចថ្មី ក្រោយបានទទួលការបណ្តុះបណ្តាលជំនាញមូលដ្ឋាន ៣៥០ គ្រួសារ, (១០).មន្ត្រីរាជការក្រសួងដែលទទួលបានការពង្រឹងសមត្ថភាព ដល់៨០ម៉ោងក្នុងមួយឆ្នាំៗក្នុងម្នាក់ៗចំនួន ៦០ម៉ោង/ម្នាក់, (១១).ចំនួនសហគមន៍ ជនជាតិបានទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទ ១៧៣ សហគមន៍។

ជាក់ស្តែងក្នុងឆ្នាំ ២០២១ នេះ ក្រសួងសម្រេចបានលទ្ធផលធំៗជាច្រើនដូចខាងក្រោម៖

**២.១.កម្មវិធីទី១.ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍ គឺជាកត្តាដ៏សំខាន់សម្រាប់ទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច និងសង្គមកិច្ច រួមចំណែកដល់កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ក្នុងន័យនេះ ដើម្បីជំរុញតំបន់ជនបទឱ្យមានការវិវឌ្ឍរីកចម្រើនយ៉ាងឆាប់រហ័ស ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការតភ្ជាប់មួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ គ្របដណ្តប់លើផ្នែកគមនាគមន៍ដឹកជញ្ជូន ទឹកស្អាត និងអនាម័យជនបទ ដែលផ្តល់អត្ថប្រយោជន៍ដល់ការលើកកម្ពស់ជីវភាព និងសុខុមាលភាពក្នុងការរស់នៅរបស់ប្រជាជនជនបទ។ ក្នុងឆ្នាំ២០២១នេះ ក្រសួងទទួលថវិកាសរុបចំនួន ៣៣៤ ៣៥៥ លានរៀល ក្នុងនោះថវិកាចរន្តចំនួន ២៦៧ ៥៩៩ លានរៀល ក្រោយវិចារណកម្មនៅសល់ ២៥៥ ៣៩៦,៦ លានរៀល ដោយបានអនុវត្តចំណាយចរន្តបាន ១០៨ ៤៧៤,៦ លានរៀល ស្មើនឹង ៤២% និងចំណាយមូលធនបាន ១៧៥ ៤៨៣ លានរៀល ស្មើនឹង ៦៩% ដោយសម្រេចគោលដៅបាន ៩៤%។

ជាក់ស្តែងក្នុង ឆ្នាំ២០២១ នេះ ស្ថិតក្រោមហិរញ្ញប្រទានថវិការដ្ឋ ថវិកាដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ក្រសួងបានសម្របសម្រួល និងសហការអនុវត្តគម្រោងនៅតាមបណ្តារាជធានីខេត្ត ទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងអភិវឌ្ឍន៍ជនបទបានស្ថាបនាផ្លូវថ្មី សរុបប្រវែង ២ ៥២២,១៥ គ.ម (ក្នុងនោះផ្លូវកៅស៊ូពីរជាន់ប្រវែង ៥០០,៥២ គ.ម ផ្លូវបេតុងប្រវែង ១,១៤ គ.ម ផ្លូវក្រួសក្រហម ២០២០,៤៩គ.ម) តិចជាងសូចនាករមេប្រវែង ៥៧៨,៨៥គ.ម ស្មើនឹង ៨១,៣៣% នៃគោលដៅដែលបានកំណត់ប្រវែង ៣ ១០១ គ.ម ក្នុងឆ្នាំ២០២១ ក្នុងនោះ ផ្លូវជនបទដែលបានកែលម្អទៅជាកៅស៊ូពីជាន់ ឬបេតុងដើម្បីធន់នឹងការប្រែប្រួលអាកាសធាតុសម្រេចបាន ៥០១,៨៥គ.ម លើសសូចនាករមេប្រវែង ៣២៩,៨៥ គ.ម ស្មើនឹង ២៩១,៧៧% នៃគោលដៅដែលបានកំណត់ត្រឹម ១៧២ គ.ម ក្នុងឆ្នាំ២០២១, ជួសជុល ថែទាំផ្លូវជនបទបានប្រវែង ៦ ៥៦៥,៦៥ គ.ម (ជួសជុលផ្លូវកៅស៊ូ ៤៣,១២ គ.ម) លើស សូចនាករមេចំនួន ៤ ៤១៧,៦៥ គ.ម ស្មើនឹង ៣០៥,៦៦% នៃគោលដៅដែលបានកំណត់ប្រវែង ១២ ៨៨៦ គ.ម, សំណង់សិល្បការមាន៖ ស្ពានបេតុងចំនួន ១៣កន្លែង ប្រវែង ២២៥ ម, លូមូលបង្ហូរទឹក ៩៤២កន្លែង លូប្រអប់ ៤៨កន្លែង ដាក់ស្លាកសញ្ញាចរាចរចំនួន១០៧៣កន្លែង។ ក្នុងនោះមាន ៖

**ក-គម្រោងហិរញ្ញប្បទានថវិកាជាតិ**

អនុកម្មវិធីទី១ នៃកម្មវិធីទី១ ស្តីពីការជួសជុល និងរក្សាគុណភាពផ្លូវជនបទទទួលបានថវិកា

សរុប ចំនួន ១០០ ០២៨,៥ លានរៀល ក្រោយវិចារណកម្មនៅសល់ចំនួន ៩៩ ៨៦៣,៣ លានរៀល អនុវត្តបាន ៩២ ៨១៣ លានរៀល ស្មើនឹង ៩៣% ដោយមានគម្រោងថែទាំ និងជួសជុលផ្លូវជនបទ ចំនួន ៤៦៤ ខ្សែ ប្រវែង ៤ ២៩៨,៣៦ គ.ម ក្នុង២៤ខេត្ត សម្រេចបាន ៣ ២៩១,៤៤ គ.ម ស្មើនឹង ៧៦,៥៧% ក្នុងនោះ ការថែទាំផ្លូវ ក្រួសក្រហមជាលក្ខណៈខួបប្រវែង ៤៧៥,២៥ គ.ម សម្រាប់ ២៤ ខេត្ត សម្រេចបាន ៣៨៣,២ គ.ម ស្មើនឹង ៨១% និងផ្លូវកៅស៊ូពីរជាន់ ១៨,៦ គ.ម សម្រាប់ផ្លូវ ៤ខេត្ត សម្រេចបាន ៤៣,១២ គ.ម ស្មើនឹង ២៣១%។ ថែទាំផ្លូវក្រួសក្រហមជាលក្ខណៈប្រចាំប្រវែង ២ ៥៣៧,១៨ គ.ម សម្រាប់ ២៥ ខេត្ត សម្រេចបាន ១ ៧៨៩,៤ គ.ម ស្មើនឹង ៧១% និងផ្លូវកៅស៊ូពីរជាន់ ១ ១៦០,៥៣ គ.ម សម្រាប់១៣ ខេត្ត សម្រេចបាន ៩៦៨,៩១ គ.ម ស្មើនឹង ៨៤% និងជួសជុលផ្លូវជាលក្ខណៈបន្ទាន់ សរុបប្រវែង ១០៦,៨០ គ.ម សម្រាប់ ២៤ ខេត្ត សម្រេចបាន ១០៦,៨០ គម ស្មើនឹង ១០០% ។

**អនុកម្មវិធីទី២ នៃកម្មវិធីទី១ ស្តីពីការពង្រីកវិសាលភាពនៃការស្តាបនា លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទបានទទួល**ថវិកាជំពូក ២១ ចំនួន ១៥០ ០០០ លានរៀល ក្រោយវិចារណកម្មនៅសល់ ១៣៨ ១០០ លានរៀល និងបានចំណាយអស់ ១៧៥ ៤៨២,៥ លានរៀល ស្មើនឹង ១២៧%ដោយមានគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ និងសំណង់សិល្បការ្យមានចំនួន ៥៧ គម្រោង សាងសង់ផ្លូវក្រាលក្រួសក្រហមបានប្រវែង ១១៤ គ.ម នៅខេត្តចំនួន ៨ សម្រេចបាន ១០៥,៨៣ គ.ម ស្មើនឹង ៩៣% , គម្រោងសាងសង់ និងកែលម្អផ្លូវក្រាលកៅស៊ូពីរជាន់ និងបេតុងបានប្រវែង ១៤៤ គ.ម ក្នុងខេត្តចំនួន ១២ សម្រេច ១៥៥,៤២ គ.ម ស្មើនឹង ១០៨% នៃផែនការ, សាងសង់ស្ពានបេតុងចំនួន ០៩ កន្លែង ប្រវែងសរុប ២២៥ ម, សាងសង់លូមូលចំនួន ៣៨៦កន្លែង, លូប្រអប់ចំនួន ៤៨កន្លែង, លូបង្ហៀរ និងលូអ៊ុយចំនួន ៨១កន្លែង, ដាក់ស្លាកសញ្ញាចរាចរ និងស្លាកគម្រោង សរុបចំនួន ១ ០៧៣ កន្លែង។

**អនុកម្មវិធីទី៣ កម្មវិធីទី១ ការរៀបចំបញ្ជីសារពើភណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ** បានទទួលថវិកាចំនួន ៤៤៧,៥ លានរៀល ក្រោយវិចារណកម្មនៅសល់ ៣១០,៣ លានរៀល អនុវត្តបាន ២០៤,៥ លានរៀល ស្មើនឹង ៦៦% ដោយមានគម្រោងរៀបចំធ្វើបច្ចុប្បន្នភាពខ្សែផ្លូវជនបទ បញ្ចូលក្នុងសៀវភៅបញ្ជីសារពើភ័ណ្ឌផ្លូវជនបទក្នុងក្របខណ្ឌ ទូទាំងប្រទេស ចំនួន ៤៨ ៩៣២ គ.ម និងផលិតផែនទី ១២៥ ផ្ទាំង។ ជាលទ្ធផលសម្រេចបាន ៣៩ ១៤៦ គ.ម ស្មើនឹង ៨០% និងផលិតផែនទីផ្លូវជនបទបាន ១០០ផ្ទាំង ស្មើនឹង ៨០%។

**អនុកម្មវិធីទី៤ កម្មវិធីទី១ ស្តីពីការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធជនបទដោយមន្ទីរជំនាញរាជធានីទាំង ២៥** បានទទួលថវិកាសរុប ១៧ ១២៣ លានរៀល អនុវត្តចំណាយបានចំនួន ១៥ ៧៥៦,១ លានរៀល ស្មើនឹង ៩២,០២% ដោយសម្រេចលទ្ធផលបាន៖ សាងសង់ផ្លូវក្រាលបេតុង ១ខ្សែប្រវែង ១,១៤ គ.ម, កែលម្អផ្លូវជនបទធន់នឹងការប្រែប្រួលអាកាសធាតុ(DBST) ប្រវែង ២៤គ.ម។ ការជួលជុល ថែទាំផ្លូវជនបទជាលក្ខណៈប្រចាំចំនួន ១៣៨ ខ្សែ ប្រវែង ២៣៩,២៥ គ.ម, ការជួសជុលថែទាំផ្លូវលំជនបទ ជាលក្ខណៈខួប ៩ ខ្សែ ប្រវែង ៤១,៩ គ.ម, ជួសជុលស្ពាន ១០ កន្លែង។ ការរាប់ចំនួនចរាចរយានយន្ត ៥៧៦ លើក, ការថែទាំផ្លូវទប់ទល់នឹងបម្រែបម្រួលអាកាសធាតុដោយបានកប់គ្រាប់ត្នោតចំនួន ៩ ២០០ គ្រាប់ និងដាំកូនឈើបានចំនួន ៤១ ៩៩០ ដើម។ រៀបចំទីទួលសុវត្ថិភាពចំនួន ៥ កន្លែង និង ត្រួតពិនិត្យ

ការដឹកជញ្ជូនលើសទំងន់លើផ្លូវជនបទចំនួន ១០៩ លើក។ រៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវជនបទ ប្រវែង ១៩៨,៦ គ.ម ធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវជនបទចំនួន ៥២២,៥៤ គ.ម។

គម្រោងសាច់ប្រាក់ពលកម្មដែលជាគោលនយោបាយដ៏ត្រឹមត្រូវ និងចំគោលដៅរបស់រាជរដ្ឋាភិបាល សម្រាប់ផ្ដល់ការងារជូនប្រជាពលរដ្ឋដែលរស់នៅ ឬវិលត្រឡប់ទៅគេហដ្ឋាននៅជនបទហើយបានបាត់បង់ការងារពីទីក្រុង ឬពីក្រៅប្រទេសដោយសារវិបត្តិនៃជំងឺកូវីដ-១៩ ឬដោយសារការផ្អាក ឬបិទរោងចក្រវាយណភ័ណ្ឌ។ គម្រោងនេះ ជាគម្រោងកសាងផ្លូវលំ ដោយប្រើប្រាស់តែកម្លាំងប្រជាជនសុទ្ធសាធ ហើយបានផ្ដល់ប្រាក់កម្រៃសមរម្យក្នុងការលើកគួផ្លូវជីស និងដាំស្មៅជើងទេផ្លូវ។ ជាលទ្ធផលក្នុងឆ្នាំ ២០២១ គម្រោងសាច់ប្រាក់ពលកម្ម អនុវត្តលើការងារជីសចំនួន ៧២៩ អនុគម្រោងប្រវែង ១ ០០២, ៣៨ គ.ម ស្មើនឹង ១០០ % ក្នុងខេត្តគោលដៅទាំង១៧។ ការងារក្រាលក្រួសក្រហមសម្រេចបានចំនួន ៥៦១ កិច្ចសន្យាប្រវែង ១ ៧៧៥,៤៦៤ គ.ម ស្មើនឹង៧២% នៃកិច្ចសន្យា ៧៦៣ ប្រវែង ២ ៤៤៦,២៣៧ គ.ម និងបានកំពុងអនុវត្តចំនួន ២០២ កិច្ចសន្យា ប្រវែង ៦៧០,៧៧៣ គ.ម ក្នុងខេត្ត គោលដៅទាំង១៧។

### ខ-គម្រោងហិរញ្ញប្បទានថវិកាដៃគូអភិវឌ្ឍន៍

ក្នុងន័យបំពេញបន្ថែមទាំងលទ្ធភាព និងសមត្ថភាពនោះ រាជរដ្ឋាភិបាលបានបើកទូលាយកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយដៃគូអភិវឌ្ឍន៍ ទាំងបណ្ដាប្រទេសជាមិត្ត និងអង្គការជាតិនិងអន្តរជាតិនានា ដោយស្មើភាពតាមគោលការណ៍ "កែទម្រង់ខាងក្នុង បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ" ក្រោមរូបភាព ទ្វេភាគី ពហុភាគី និងទំនាក់ទំនងជាសាធារណៈ។ ក្នុងឆ្នាំ ២០២១នេះ ក្រសួងបានសហការអនុវត្តគម្រោង ជាមួយដៃគូខាងលើ ទទួលបានលទ្ធផលដូចខាងក្រោម៖

**ទី១.** គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ ក្រោមហិរញ្ញប្បទាន សហប្រតិបត្តិការពីធនាគារពិភពលោក។ គម្រោងមានគោលបំណងធ្វើឲ្យប្រសើរឡើងដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋរស់នៅក្នុងខេត្តគោលដៅទាំង ៦ គឺ ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកណ្ដាល និងខេត្តសៀមរាប ដើម្បីងាយស្រួលក្នុងការធ្វើដំណើរទៅកាន់ទីផ្សារ ងាយស្រួលស្វែងរកការងារធ្វើ ងាយស្រួលក្នុងការទទួលបានសេវាសង្គម និងសុវត្ថិភាពសង្គម ភាពធន់នឹងអាកាសធាតុ និងប្រសិទ្ធភាពចំណាយលើការកែលម្អបណ្ដាញផ្លូវជនបទ ដែលអាចឲ្យប្រជាពលរដ្ឋធ្វើដំណើរបានគ្រប់រដូវកាលនៅក្នុងតំបន់ដែលមានវិសាលភាពកសិកម្មខ្ពស់នៃខេត្តគោលដៅ។ គម្រោងមានគោលបំណង ក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌរស់ នៅសម្រាប់គ្រួសារនីមួយៗនៅជនបទ តាមរយៈការអភិវឌ្ឍផ្លូវជនបទ។ ជាលទ្ធផល គម្រោងបានសាងសង់ផ្លូវចំនួន ៧ខ្សែ ប្រវែង ៤៩,៨៩ គ.ម ក្នុងខេត្តកណ្ដាល, សាងសង់ផ្លូវ ៦ខ្សែ ប្រវែង ៤៥,៣២៨ គ.ម ក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង(សម្រេចបាន ៤១,១៤%)។ សាងសង់ផ្លូវ ៨ខ្សែ ប្រវែង ៧៦,៨៨៥ គ.ម ក្នុងខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប។

**ទី២.** គម្រោងកែលម្អផ្លូវជនបទជំហានទី ៣ (RRIP-III) ជាហិរញ្ញប្បទានសម្បទានរបស់ធនាគារ អភិវឌ្ឍន៍ អាស៊ី (ADB) បាននិងកំពុងដំណើរការស្ថាបនាផ្លូវជនបទ ក្រាលកៅស៊ូពីរជាន់ សរុប

ប្រវែង ៣៥៩,៨ គ.ម នៅក្នុងខេត្តគោលដៅចំនួន៥គឺ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តក្រចេះ។ ឆ្នាំ២០២១ គម្រោងស្ថាបនាផ្លូវក្រាលកៅស៊ូពីរជាន់សរុបបានចំនួន ២០ ខ្សែ ប្រវែងសរុប ៣៤០,៨០ គ.ម ស្ថាបនាស្ពាន ៣កន្លែង លូមូល លូប្រអប់ សរុបចំនួន ៥៥៦កន្លែង ដោយសម្រេចបាន ៥២,៨៨% នៃផែនការ ក្នុងនោះខេត្តត្បូងឃ្មុំមានផ្លូវក្រាលកៅស៊ូពីរជាន់ចំនួន ០២ខ្សែ ប្រវែង ២៣,៧ គ.ម លូមូលចំនួន ៣៨កន្លែង សម្រេចបាន ១០០%។ ដោយឡែក គម្រោងហិរញ្ញប្បទានរបស់សាធារណរដ្ឋកូរ៉េ (EDCF) គ្រោងនឹងស្ថាបនាផ្លូវក្រាលកៅស៊ូពីរជាន់ សរុបប្រវែង ៣៦៣,៦៦ គ.ម ស្ពានចំនួន ១១កន្លែង លូប្រអប់ចំនួន ៧១កន្លែង, លូមូល ចំនួន ៤២៥កន្លែង, នៅក្នុងខេត្តចំនួន ០៥ គឺខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត និងខេត្តកណ្ដាល ទើបតែសម្រេចបានបាន ១,១៨% នៅឡើយទេ។

**ទី៣.** គម្រោងកម្មវិធីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ ជំហានទី ៥ (RIP-V) ថវិកាបដិភាគរបស់រដ្ឋ ៣,៣ លានដុល្លាសហរដ្ឋអាមេរិក ចូលរួមចំណែកធ្វើការថែទាំផ្លូវជាលក្ខណៈខួប, ខ្សែផ្លូវដែលជាជំនួយឥតសំណងរបស់ធនាគារ KfW កន្លងមកក្នុងខេត្តចំនួន១២ គឺ ៖ ខេត្តកំពង់ស្ពឺ ខេត្តបាត់ដំបង ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម និងខេត្តព្រៃវែង។ ឆ្នាំ២០២១ ផ្លូវថែទាំខួបក្នុងខេត្តទាំង ១២ សម្រេចបាន ១៥ខ្សែ សរុបប្រវែង ២១៦,០៦០ គ.ម សម្រេចបាន ១០០%នៃផែនការ។

**ទី៤.** គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន(CFAVC) **មានរយៈពេល** ៦ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៤ ក្រោមការគាំទ្រហិរញ្ញប្បទាន ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងមូលនិធិអាកាសធាតុបៃតង មានថវិកាសរុប ចំនួន ១៤១ ០៤០ ០០០ ដុល្លារអាមេរិក។ ឆ្នាំ ២០២១នេះ គម្រោងបានបញ្ចប់នីតិវិធីលទ្ធកម្មរួចហើយលើផ្លូវប្រវែងសរុបចំនួន ៧១ គ.ម នៃផែនការឆ្នាំ២០២០។ គម្រោងនេះមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ធនាគារអភិវឌ្ឍន៍អាស៊ី(ADB), មូលនិធិអាកាសធាតុបៃតង, កំពុងសិក្សាប្លង់បច្ចេកទេស និងត្រួតពិនិត្យការអនុវត្តគម្រោង ដើម្បីធ្វើឱ្យប្រសើរឡើងដល់សហគមន៍កសិកម្មខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តតាកែវ និងខេត្តកំពត។

**ទី៥.** គម្រោងផ្គត់ផ្គង់ទឹកជនបទ និងគម្រោងកែលម្អផ្លូវជនបទជំហាន២ ក្រោមហិរញ្ញប្បទានឥតសំណង់ពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនសរុបចំនួន ៣៧៨ ៧២០ ០០០ RMB ស្ថាបនាផ្លូវជនបទក្រាលកៅស៊ូ ប្រវែងសរុប ១១៩,៤៦៧ គ.ម ក្នុងខេត្តគោលដៅចំនួន ០៦ រួមមាន ៖ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកណ្ដាល ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ ក្នុងនោះក្រុមហ៊ុន Shanghai Construction Group Co., Ltd. នឹងត្រូវធ្វើការសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ៧៩,១៣៧ គ.ម នៅក្នុងខេត្តចំនួន ០៣ រួមមានខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ និងខេត្តកណ្ដាល បច្ចុប្បន្ន គម្រោងអនុវត្តសម្រេចបាន ៩២,២៦% និងក្រុមហ៊ុន YUNNAN CONSTRUCTION AND INVESTMENT HOLDING GROUP CO., LTD. នឹងត្រូវធ្វើការសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ៤០,៤១ គ.ម នៅក្នុងខេត្តចំនួន ០៣ រួមមាន ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង និងខេត្តស្វាយរៀង អនុវត្តបាន ៧១,៧៦%។ ដើម្បីចូលរួមក្នុងការថែរក្សាបរិស្ថាន និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ

គម្រោងកែលម្អផ្លូវជនបទដំណាក់កាលទី ២ បានដាំដើមឈើ ប្រភេទអាកាស្យាស្លឹកធំចំនួន ៩១ ២៨៧ ដើម នៅតាមដងផ្លូវរបស់គម្រោងក្នុងខេត្តគោលដៅ និងចែកកូនឈើហូបផ្លែជូនគ្រួសារក្រីក្របាន ចំនួន ៣៩២០ ដើម។

### ២.២.កម្មវិធីទី២.ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

កម្មវិធីកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ នៃប្រទេសកម្ពុជាមានគោលដៅកែលម្អសុខុមាលភាពនៃការរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅតាមជនបទឲ្យបានល្អប្រសើរឡើង ដើម្បីកាត់បន្ថយជម្ងឺដម្កាត់ផ្សេងៗមួយចំនួនដែលបណ្តាលមកពី ការរស់នៅគ្មានអនាម័យ ការប្រើប្រាស់ និងបរិភោគទឹកមិនស្អាត រស់ក្នុងបរិស្ថានមិនល្អ ការបំពុលបរិស្ថាន ការចោលសំរាម ការបន្ទោរបង់ពាសវាលពាសកាល។ល។ ក្រសួងបានផ្តល់អាទិភាពងាយស្រួលដល់សហគមន៍ជនបទ ឱ្យទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត ការសំអាត និងអនាម័យជនបទ តាមរយៈការបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ស្រទាប់ប្រជាជនគ្រប់លំដាប់ថ្នាក់ ឱ្យចេះផ្លាស់ប្តូរទម្លាប់ទាំងនេះ និងកែលម្អលក្ខខណ្ឌនៃការរស់ប្រកបដោយផាសុកភាព និងសុវត្ថិភាព ស្របតាមចក្ខុវិស័យរយៈពេលវែង "ឆ្នាំ២០២៥ ប្រជាពលរដ្ឋគ្រប់រូបនៅសហគមន៍ជនបទ ត្រូវមានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព" ស្របតាមគោលការណ៍សំខាន់ៗ ចំនួន ០៣ គឺះ (១).ការប្រើប្រាស់បង្គន់អនាម័យឱ្យបានគ្រប់គ្នា (២).មានទម្លាប់លាងសម្អាតដៃជាមួយសាប៊ូក្រោយពេលបន្ទោរបង់និងមុនបរិភោគអាហារ និង(៣).ហូបទឹកដែលមានសុវត្ថិភាព។ កម្មវិធីកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ ត្រូវបានអនុវត្តចម្រុះក្នុងនោះមាន ក្រសួងអភិវឌ្ឍន៍ជនបទ, ធនាគារអភិវឌ្ឍអាស៊ី, ធនាគារពិភពលោក, អង្គការ UNICEF, គម្រោងទ្វេភាគីជាមួយប្រទេសចិន, គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាងជាជំនួយឥតសំណងពីសាធារណៈប្រជាមានិតចិន, គម្រោងសហប្រតិបត្តិការជាមួយសាធារណៈឥណ្ឌា ( Quick Impack Project) និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៤១ ទៀត ក្នុងកម្មវិធីទឹកស្អាត, សុខភាព អនាម័យ, អប់រំផ្សព្វផ្សាយ, បណ្តុះបណ្តាលជំនាញកសិកម្ម និងអភិវឌ្ឍន៍សហគមន៍ចម្រុះ។ ក្នុងឆ្នាំ២០២១នេះ ក្រសួងបានទទួលថវិកាចំនួន ១១ ៣៤៧,៦០ លានរៀល ក្រោយវិចារណកម្មនៅសល់ ៩៩៤១,៤ លានរៀល អនុវត្តបាន ៥០៦០,០៤ លានរៀល ស្មើនឹង ៥១% ដោយសម្រេចគោលដៅបាន ៧៨,៨% លើសសូចនាករមេ ០,៨% នៃគោលដៅដែលបានកំណត់ ៧៨ % នៅឆ្នាំ២០២១ សម្រាប់សេវាទឹកស្អាតជនបទ និងការផ្តល់សេវាអនាម័យជនបទសម្រេចបាន ៧៨,៥% តិចជាងគោលដៅ ៥,៥% ដែលបានកំណត់បាន ៨៤% ក្នុងឆ្នាំ២០២១។ សូចនាករការបញ្ឈប់បន្ទោរបង់ពាសវាលពាសកាល ODF សម្រេចបាន ១ ខេត្ត (ខេត្តស្វាយរៀង) ក្នុងចំណោមគោលដៅ ៣ ខេត្ត គិតត្រឹមឆ្នាំ២០២១ ពោលគឺអាចសម្រេចបានត្រឹម ៣៣,៣៣% នៃគោលដៅប៉ុណ្ណោះបើធៀបនឹងសូចនាករគោល ក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៩-២០២៣ (NSDP 2019-2023)។ លទ្ធផលរួមសម្រេចបាន ក្នុងវិស័យទឹកស្អាត និងអនាម័យមានសាងសង់អណ្តូងទឹកគ្រប់ប្រភេទបានចំនួន ៣ ២៦០អណ្តូង, ជួសជុលអណ្តូង គ្រប់ប្រភេទសរុបចំនួន ៣៦៦ អណ្តូង, សាងសង់ស្រះសហគមន៍សរុបចំនួន ៦២៥ស្រះ (ស្រះ៤២ មានជញ្ជាំងបេតុង) ស្តារស្រះឡើងវិញបាន ៤ស្រះ, សាងសង់ពាងទឹកចំនួន ៦១ ៧៦៧ពាង, សាងសង់អាងត្រងទឹកភ្លៀង ចំនួន

១ ៨៤៥អាង, សាងសង់ប្រព័ន្ធចែកចាយទឹកចម្រុះ ៥៥០កន្លែង, ចែកធុងចម្រុះ ២០លីត្រចំនួន ២ ១៥៨ធុង, ចែកអាងត្រងទឹកភ្លៀងផ្លាស្ទិកចំណុះ ១ ០០០លីត្រ ចំនួន ៩៩គ្រួសារ។ សាងសង់បង្គន់អនាម័យចំនួន ៣៤ ១៧៦បង្គន់ (ក្នុងនោះបង្គន់សាធារណៈ១៣៧បង្គន់) សាងសង់កន្លែងលាងដៃបាន ៥កន្លែង, ចែកធុងលាងសំអាតដៃចំនួន ៣ ០០៣ធុង។

ផ្សព្វផ្សាយ អប់រំណែនាំប្រជាជននៅតំបន់ជនបទ ឱ្យយល់ដឹងពីរបៀបធ្វើអនាម័យផ្ទាល់ខ្លួន បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល (ODF) ហើយងាកមករកការបន្ទោរបង់ក្នុងបង្គន់ដែលសាងសង់ឡើងតាមក្បួនខ្នាតត្រឹមត្រូវ លាងសំអាតដៃមុននិងក្រោយទទួលទានអាហារ និងបន្ទាប់ពី ទទួលទានអាហាររួចបានចំនួន ៤០៩៣ភូមិ។ ទទួលទានទឹកស្អាតដែលមានសុវត្ថិភាព រក្សាទឹកទុកប្រើប្រាស់ឱ្យបានត្រឹមត្រូវ រក្សាទឹកទុកនៅពេលជួបគ្រោះរាំងស្ងួត។ ផ្សព្វផ្សាយ អប់រំប្រជាជនស្តីពីអនាម័យ តាមគ្រួសារ និងសហគមន៍រស់នៅស្អាតបាន ១០ ៩៣០ នាក់។

**ក-គម្រោងហិរញ្ញប្បទានថវិកាជាតិ**

អនុកម្មវិធីទី១ នៃកម្មវិធីទី២ ស្តីពីការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទ បានទទួលថវិកា ៥ ៦០៥,៧ លានរៀល ក្រោយវិចារណកម្មនៅសល់ ៩ ៩៤១,៤ លានរៀល អនុវត្តបាន ២ ២៤២,២៨ លានរៀល ស្មើនឹង ៤០% ដោយមានគម្រោងសាងសង់អណ្តូងស្នប់ចំនួន ៣១៥ អណ្តូង សម្រាប់ ២១ ខេត្ត ក្នុងនោះខេត្តបាត់ដំបង ១៧ អណ្តូង, ខេត្តកំពង់ចាម ១៦ អណ្តូង, ខេត្តកំពង់ឆ្នាំង ២៨ អណ្តូង, ខេត្តកំពង់ស្ពឺ ២០ អណ្តូង, ខេត្តកំពង់ធំ ១២ អណ្តូង, ខេត្តកំពត ២ អណ្តូង, ខេត្តកណ្តាល ២៦ អណ្តូង, ខេត្តក្រចេះ ២៣ អណ្តូង, ខេត្តមណ្ឌលគិរី ៨ អណ្តូង, ខេត្តឧត្តរមានជ័យ ១២ អណ្តូង, រាជធានីភ្នំពេញ ១០ អណ្តូង, ខេត្តព្រះសីហនុ ១២ អណ្តូង, ខេត្តព្រៃវែង ៣ អណ្តូង, ខេត្តពោធិ៍សាត់ ១៥ អណ្តូង, ខេត្តរតនគិរី ៦ អណ្តូង, ខេត្តសៀមរាប ១៤ អណ្តូង, ខេត្តស្ទឹងត្រែង ៣៤ អណ្តូង, ខេត្តស្វាយរៀង ៣២ អណ្តូង, ខេត្តតាកែវ ១១ អណ្តូង, ខេត្តត្បូងឃ្មុំ ១៤ អណ្តូង ដោយសម្រេចបាន ១០០%។ សាងសង់ស្រះទឹកសហគមន៍ចំនួន ៩ សម្រាប់ ៧ ខេត្ត ក្នុងនោះខេត្តកំពង់ស្ពឺ ១ស្រះ, ខេត្តកំពត ៣ស្រះ, ខេត្តកណ្តាល ១ស្រះ, រាជធានីភ្នំពេញ ១ស្រះ, ខេត្តព្រះសីហនុ ១ស្រះ, ខេត្តព្រះវិហារ ១ស្រះ, ខេត្តតាកែវ ១ស្រះ សម្រេចបាន ១០០%។ សាងសង់អាងត្រងទឹកភ្លៀង ៤៤អាង សម្រាប់ ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី សម្រេចបាន ១០០%, សាងសង់ប្រព័ន្ធចែកចាយទឹកសហគមន៍ ៥ កន្លែង សម្រាប់ ៥ខេត្ត ក្នុងនោះ ខេត្តបន្ទាយមានជ័យ ១កន្លែង, ខេត្តកែប ១កន្លែង, ខេត្តកោះកុង ១កន្លែង, ខេត្តប៉ៃលិន ១កន្លែង, ខេត្តព្រះវិហារ ១កន្លែង សម្រេចបាន ១០០%។ ចែកធុងចម្រោះ ១០៨ធុង នៅខេត្តឧត្តរមានជ័យ និងស្តារប្រឡាយ ១ខ្សែប្រវែង ១ ៥៨៨ម នៅខេត្តព្រៃវែង។ បានចុះត្រួតពិនិត្យទឹក អណ្តូងដើម្បីរកសារធាតុអាសេនិច ចំនួន ៧៩ សំណាក។ ចុះសិក្សាទីតាំងសម្រាប់ធ្វើប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ ស្រះទឹក។ ចុះធ្វើតេស្តគុណភាពទឹក ដើម្បីពិនិត្យសារធាតុអាសេនិច ក្នុងអណ្តូងស្នប់ថ្មីដែលមិនទាន់បានធ្វើតេស្តកន្លងមក ចំនួន ៧៥ អណ្តូង។ ចុះត្រួតពិនិត្យការសាងសង់ អណ្តូងស្នប់ ចំនួន ៦៤ អណ្តូង។

អនុកម្មវិធីទី២ នៃកម្មវិធីទី២ ស្តីពី ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាត បានទទួល

ថវិកា ៦៥១ លានរៀល ក្រោយវិចារណកម្មនៅសល់ ៤១១,៨ លានរៀល អនុវត្តចំណាយបានចំនួន ៤០៥,៨១ លានរៀល ស្មើនឹង ៩៩% សម្រាប់រៀបចំសិក្ខាសាលា ៩ លើកនិងចុះតាមដាន ការអនុវត្តផែនការ ២៤ ខេត្ត ដោយសម្រេចបាន ៩៩ % លើកលែងតែការប្រារព្ធទិវាទឹកពិភពលោកពុំបានអនុវត្ត។

អនុកម្មវិធីទី៣ នៃកម្មវិធីទី២ ស្តីពីការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តអនាម័យជនបទ ទទួលបានថវិកាចំនួន ២ ៣៣៧,១ លានរៀល ក្រោយវិចារណកម្មនៅសល់ ១ ៤៦១,៦៤ លានរៀល អនុវត្តចំណាយបានចំនួន ៥៧៩,៩ លានរៀល ស្មើនឹង ៤០% ដោយគ្រោងសាងសង់បង្គន់គ្រួសារជូនប្រជាជនក្រីក្រចំនួន ៣ ៥០១គ្រួសារ និងផ្តល់សម្ភារសង់បង្គន់អនាម័យ (បង្គន់សហគមន៍ ៣ ៤៣១ និងបង្គន់តំបន់លិចទឹក ៧០) ក្នុងឃុំគោលដៅចំនួន ២៨ ក្នុងខេត្តចំនួន ១៤ គឺ ខេត្តត្បូងឃ្មុំ, ខេត្តកំពង់ចាម, ខេត្តក្រចេះ, ខេត្តឧត្តរមានជ័យ, ខេត្តសៀមរាប, ខេត្តប៉ៃលិន, ខេត្តកំពង់ឆ្នាំង, ខេត្តកំពង់ស្ពឺ, ខេត្តព្រះសីហនុ, ខេត្តព្រៃវែង, ខេត្តព្រះវិហារ, ខេត្តស្វាយរៀង, ខេត្តកោះកុង និងខេត្តកែប។ ជាលទ្ធផលការងារសម្រេច ១ ២៨០ គ្រួសារ ស្មើនឹង ៥២% និងបានចុះស្រង់ទិន្នន័យ ១២០ ភូមិស្មើនឹង ១០០% ក្នុងខេត្តគោលដៅ ទាំង១៤ ខាងលើ។

អនុកម្មវិធីទី៤ នៃកម្មវិធីទី២ ស្តីពីការលើកកម្ពស់ការរស់នៅស្អាត ការអប់រំសុខភាពនិងអនាម័យជនបទបាន ទទួលថវិកាចំនួន ៨១៣,៩ លានរៀល ក្រោយវិចារណកម្មនៅសល់ ៥២២,៣៨ លានរៀល និងអនុវត្តចំណាយ ចំនួន ៥២,២០ លានរៀលប៉ុណ្ណោះ ដោយបានចុះត្រួតពិនិត្យការងារអនាម័យបាន ៦០ដង លើកកម្ពស់ការយល់ដឹងអនាម័យតាមរយៈប្រព័ន្ធផ្សព្វផ្សាយ បានពីរលើក និងបោះពុម្ព សម្ភារៈអប់រំអនាម័យបាន ១៥ ឈុត ដោយសម្រេចបាន ៣១%។

អនុកម្មវិធីទី៥ នៃកម្មវិធីទី២ ស្តីពីការផ្តល់សេវាសុខភាព និងលក្ខខណ្ឌនៃការរស់នៅសម្រាប់សាធារណៈជន ដោយមន្ទីររាជធានីខេត្ត ទាំង ២៥ បានទទួលថវិកា ១ ៩៣៩,៩ លានរៀល អនុវត្តចំណាយចំនួន ១ ៧៨៤,៧១ លានរៀល ស្មើនឹង៩២% និងសម្រេចការងារបាន ៨៣% នៃផែនការឆ្នាំ។ ជាលទ្ធផលសម្រេចបានស្តារប្រឡាយស្រោចស្រព ២ខ្សែ ប្រវែង ៦គ.ម, សាងសង់អណ្តូងទឹក គ្រប់ប្រភេទចំនួន ៤៧អណ្តូង, ថែទាំនិងជួសជុលអណ្តូងចំនួន ២៣៦អណ្តូង, សាងសង់ប្រព័ន្ធចែកចាយទឹក១កន្លែង, ស្តារស្រះសហគមន៍បាន ៤ ស្រះ, សាងសង់អាងត្រងទឹកភ្លៀងបាន២៥ អាង, សាងសង់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតចម្រុះបាន ១១កន្លែង, ចុះស្រង់ទិន្នន័យបញ្ជីសារពើភណ្ឌអណ្តូង ១២៥ អណ្តូង, ផ្សព្វផ្សាយការប្រើប្រាស់ទឹកស្អាតបាន ១៤ លើក, សិក្ខាសាលារៀបចំផែនការសុវត្ថិភាពទឹក ៦៦វគ្គ, ផ្សព្វផ្សាយអនាម័យគ្រួសារបាន ២៦២ ដង, ផ្សព្វផ្សាយការបញ្ឈប់បន្ទោរបង់ពាសវាលពាសកាលបាន ២២៥ភូមិ លើកកម្ពស់ទិវាអនាម័យជាតិ ១៣វិច្ឆិកា បាន ៧លើក និងទិវាលាងសំអាតដៃ ១៥តុលា បាន ៤ លើក។

### ខ-គម្រោងហិរញ្ញប្បទានថវិកាដៃគូអភិវឌ្ឍន៍

**ទី១.**គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទជំហានទី ៣ របស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB មានគោលបំណងកែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ កែលម្អនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មអនាម័យជនបទ ពង្រឹងសមត្ថភាពស្ថាប័ន

លើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ នៅខេត្តគោលដៅចំនួន ១០ គឺៈ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។ គម្រោងសម្រេចជីកស្រះសហគមន៍បាន ២១ស្រះ, ជួសជុល អណ្តូង ខួង ២៩ អណ្តូង និងអណ្តូងលូសរុប ១០១អណ្តូង, ផលិតពាងត្រងទឹកភ្លៀងបាន ៦១ ៧៦៧ ពាង។ សាងសង់អណ្តូងថ្មីបាន ១ ៦៨៨អណ្តូង។ សាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូច សហគមន៍ ២កន្លែង។ សាងសង់បង្គន់គ្រួសារ ៨ ៥២៨ បង្គន់។ បង្គន់សាធារណៈចំនួន ១០៣ និងអាងត្រងទឹកភ្លៀងផ្លាស្ទិកចំណុះ ១០ ០០០ លីត្រ ចំនួន ៩៩។

**ទី២.** គម្រោងសាច់ប្រាក់ពលកម្ម ជាគោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់គាំទ្រផ្តល់ការងារជូនប្រជាពលរដ្ឋដែលរស់នៅ ឬវិលត្រឡប់ទៅគេហដ្ឋាននៅជនបទ ហើយបានបាត់បង់ការងារពីទីក្រុង ឬពីក្រៅប្រទេសដោយសារវិបត្តិនៃជំងឺកូវីដ-១៩ ឬដោយសារការផ្អាកឬបិទរោងចក្រវាយណភ័ណ្ឌ។ ក្នុងឆ្នាំ២០២១នេះ គម្រោងបានបន្ថែមការងារសាងសង់បង្គន់សាធារណៈនៅសាលារៀន និងមណ្ឌលសុខភាពបាន ចំនួន ៣៤ កិច្ចសន្យាស្មើនឹង ១៩០ បង្គន់។

**ទី៣.** គម្រោងផ្គត់ផ្គង់ទឹកជនបទ និងគម្រោងកែលម្អផ្លូវជនបទ ដំហាន២ ក្រោមហិរញ្ញប្បទានឥតសំណង ពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនទឹកប្រាក់ ៩០ ០២០ ០០០ RMB សម្រាប់ផ្គត់ផ្គង់ទឹកជនបទក្នុងខេត្តចំនួន១០ និងទឹកប្រាក់ ២៨៨ ៧០០ ០០០ RMB សម្រាប់ស្តាបនានិងកែលម្អផ្លូវជនបទចំនួន ៦ ខេត្តផ្សេងទៀត។ ជាលទ្ធផលគម្រោងផ្គត់ផ្គង់ទឹកជនបទ អនុវត្តដោយក្រុមហ៊ុន China Jiangxi International Economic and Technical Cooperation Co.,Ltd. ជីកអណ្តូងស្នប់បានចំនួន ៩៦៤អណ្តូង, ជីកស្រះទឹកសហគមន៍ចំនួន ១២ស្រះ, និងជីកស្រះទឹកសហគមន៍ដែលមានរៀបជញ្ជាំងថ្ម ចំនួន ៤២ស្រះ នៅក្នុងខេត្តគោលដៅចំនួន ១០ គឺ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តកំពត ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ និង ខេត្តកំពង់ចាម ។

**ទី៤.** ការប្រែក្លាយភូមិឲ្យបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល និងដំណោះស្រាយបរិស្ថានតាមដងទន្លេមេគង្គក្រោម "មូលនិធិកិច្ចសហប្រតិបត្តិការពិសេសមេគង្គឡាងឆាង" ជាជំនួយឥតសំណងរបស់សាធារណៈរដ្ឋប្រជាមានិតចិន ដោយមានថវិកាសរុបចំនួន ៤៧៨ ៤០០ ដុល្លារអាមេរិក អនុវត្តក្នុងខេត្តចំនួន០៥ រួមមាន ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ក្នុងសហគមន៍គោលដៅចំនួន ៦ស្រុក ៧ឃុំ និង ៣៨ភូមិ។ ជាលទ្ធផលគម្រោង បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីភូមិគ្មានការបន្ទោបង់ពាសវាលពាសកាល ដើម្បីបរិស្ថាននិងអនាម័យស្អាត សម្រាប់ការរស់នៅប្រកបដោយសុខុមាលភាពបានចំនួន ០៥លើក មានអ្នកចូលរួមចំនួន ៤៦៦នាក់។ រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីសហគមន៍ដឹកនាំអនុវត្តអនាម័យ និងផ្សព្វផ្សាយពីពាក្យស្លោកអប់រំស្តីពីការការពារបរិស្ថាន បានចំនួន ០៤លើក មានអ្នកចូលរួមចំនួន ៣៧៥នាក់។ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការផលិតសាប៊ូធម្មជាតិ ដោយប្រើប្រាស់ធនធានដែលមានស្រាប់ក្នុងសហគមន៍បានចំនួន ០៥វគ្គ មានអ្នកចូលរួម ចំនួន ៣៧៩នាក់។ ចែកថ្នាំពេទ្យចំនួន ០៦មុខថ្នាំ/កញ្ចប់ សម្រាប់ដោះស្រាយធុរៈបឋមបានចំនួន ១ ០០០ គ្រួសារ ក្នុងខេត្តគោលដៅ។ ចែកធុងចម្រោះទឹកបានចំនួន ១៥០ធុង។ មេសាប៊ូ

សម្រាប់ផលិតសាប៊ូក្នុងសហគមន៍បានចំនួន ១ ០០០ គ.ក។ តំឡើងផ្លាកផ្សព្វផ្សាយអប់រំ និងការបណ្តុះគំនិតឲ្យចេះស្រឡាញ់ និងការពារបរិស្ថានបានចំនួន៨០កន្លែង។ សាងសង់បង្គន់អនាម័យបានចំនួន ៨៥ខ្នង ក្នុងខេត្តគោលដៅ។ សាងសង់កន្លែងលាងដៃតាមសាលារៀន បានចំនួន ០៥កន្លែង។ ចុះពិនិត្យតាមដានការអនុវត្តគម្រោង និងសមិទ្ធផលរបស់គម្រោងតាមខេត្តគោលដៅ។ ចុះអប់រំ និងជំរុញប្រជាជន និងអាជ្ញាធរ ក្នុងការបង្កើនចំនួន បង្គន់ក្នុងសហគមន៍ ដើម្បីសម្រេចបាននូវគោលដៅភូមិគ្មានការបន្ទោរបង់ពាសវាលពាសកាល បាន ចំនួន ១៥លើក។

**ទី៥.** គម្រោងមូលនិធិកិច្ចសហប្រតិបត្តិការមេគង្គ-គង្គាជាជំនួយឥតសំណងរបស់ប្រទេសឥណ្ឌា មានគោលបំណង (១).ការប្រែក្លាយភូមិដោយគ្មានការបន្ទោរបង់ពាសវាលពាសកាល និងឥរិយាបថប្រកបដោយអនាម័យ (២).ការលុបបំបាត់ជាតិអាសេនិចក្នុងទឹកបរិភោគជុំវិញបឹងទន្លេសាប (៣).ការអភិវឌ្ឍសហគមន៍ចម្រុះ តាមរយៈទឹកស្អាត អនាម័យ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ (៤).ការការពារបរិស្ថាន តាមរយៈការលុបបំបាត់សារធាតុបំពុលក្នុងសមាសធាតុបរិស្ថាន។ គម្រោងមានថវិកាសរុបចំនួន ២០ម៉ឺនដុល្លារអាមេរិក ដោយអនុវត្តក្នុងខេត្តចំនួន០៦ រួមមាន ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តព្រៃវែង និងខេត្តស្វាយរៀង។ ជាលទ្ធផល គម្រោងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីអនាម័យ សុខភាព និងបរិស្ថាន ក្នុងការប្រែក្លាយភូមិឲ្យការក្លាយជាសហគមន៍ ODF បានចំនួន ០២លើក នៅឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ សាងសង់បង្គន់អនាម័យបានចំនួន ៥២បង្គន់។ តម្លើងប៉ាណូផ្សព្វផ្សាយអប់រំពីអនាម័យនិងបរិស្ថាន ចំនួន ២២កន្លែង។ ប្រគល់វិញ្ញាបនបត្រវាយតម្លៃ ODF ភូមិគោលដៅទាំងពីររបស់គម្រោង (ភូមិថ្មីខ្មែរ និងភូមិវាលតាគីង ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំ) ជាភូមិដែលបានបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល (វិញ្ញាបនបត្រភូមិ ODF)។ សិក្សាប្រមូលទិន្នន័យ និងកំណត់តំបន់អាសេនិចក្នុងខេត្តគោលដៅចំនួន០៤ រួមមានខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង។ ចងក្រងឯកសារ និងបោះពុម្ពសៀវភៅអាសេនិច សម្រាប់អប់រំ ផ្សព្វផ្សាយ ការការពារ និងសារធាតុអាសេនិច ១ ២០០ ក្បាល។ សាងសង់ អាងត្រងទឹកភ្លៀងចំនួន ៤០កន្លែង ក្នុងខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តសៀមរាប។ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការផលិតសាប៊ូធម្មជាតិ ដោយប្រើប្រាស់ធនធានដែលមានស្រាប់ក្នុងសហគមន៍ បានចំនួន ០២វគ្គ នៅខេត្តស្វាយរៀង និងខេត្តព្រៃវែង។ ចុះពិនិត្យតាមដានបច្ចេកទេសផលិតសាប៊ូតាមភូមិគោលដៅ។ សាងសង់កន្លែងចិញ្ចឹមមាន់បានចំនួន ០៤កន្លែង (រោងមាន់ ទំហំ ១០ម x ១២ម រួមបញ្ចូលទាំងសម្ភារចិញ្ចឹមមាន់ បច្ចេកទេសចិញ្ចឹមមាន់ ផ្តល់ពូជមាន់ ទ្រុងកូនមាន់ និងម៉ាស៊ីនភ្ញាស់ពងមាន់) នៅស្រុកស្វាយជ្រំ និងស្រុករំដួល ខេត្តស្វាយរៀង។ រៀបចំ និងចងក្រងសារអប់រំ ស្តីពីការការពារបរិស្ថាន និងការបណ្តុះគំនិតឲ្យពលរដ្ឋយល់ដឹង និងចេះស្រឡាញ់បរិស្ថាន។ ដំឡើងផ្លាកអប់រំផ្សព្វផ្សាយ ស្តីពីអនាម័យ និងការថែរក្សាបរិស្ថានជុំវិញបឹងទន្លេសាប បានចំនួន ៥០ កន្លែង (ផែនការចំនួន ៨០ផ្លាក)។ ចែកអាវ ពោងបានចំនួន ២០០អាវ ដើម្បីការពារអាយុជីវិតរបស់ប្រជាជន ពិសេសសិស្សសាលាដែលធ្វើដំណើរទៅសាលារៀនដោយជិះទូក។

**ទី៦.** ក្នុងការងារអភិវឌ្ឍន៍សហគមន៍ ក្រសួងអភិវឌ្ឍន៍ជនបទបានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដោយបានសាងសង់អណ្តូងចម្រុះចំនួន ២៤៦ អណ្តូង, សាងសង់បង្គន់អនាម័យចំនួន

២១ ៨៧៣ បង្គន់, សាងសង់ស្រះទឹកសហគមន៍ចំនួន ៥៤១ ស្រះ, សាងសង់ធុងចម្រោះទឹកស្អាត ចំនួន ១ ៩០០ធុង, សាងសង់អាងត្រងទឹកភ្លៀង ១ ៧៣៦អាង, សាងសង់ឡដុតសំរាម ២៦កន្លែង, សាងសង់ផ្ទះជូន ប្រជាជនក្រីក្របានចំនួន ៧៦ខ្នង, ចែកធុងទឹកសម្រាប់លាងដៃចំនួន ៣ ០០៣ធុង, សាងសង់ស្ថានីយ៍ចម្រោះទឹកស្អាត ៥២៥កន្លែង, ចែកផ្ទាំងសឡាសម្រាប់ដាក់បំភ្លឺនៅផ្ទះជនបទបាន ៥៥ផ្ទាំង។ សាងសង់ស្ថានីយ៍ផលិតទឹកផឹកជនបទចំនួន ០២ កន្លែង។ សាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ នៅខេត្តព្រះវិហារ ចំនួន ០៤ កន្លែង។

### ២.៣. កម្មវិធីទី៣៖ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

កម្មវិធីទី៣ នេះ បានទទួលថវិកាចំនួន ៣ ៦៦៧,១០ លានរៀល ក្រោយវិចារណកម្មនៅសល់ ២ ៧៤០,១០ លានរៀល អនុវត្តបានចំនួន ៤៦៨,៩០ លានរៀល ស្មើនឹង ១៧,១% ដោយសម្រេចគោលដៅបាន ២០%។

### ក-គម្រោងហិរញ្ញប្បទានថវិកាជាតិ

អនុកម្មវិធីទី១ នៃកម្មវិធីទី៣ ស្តីពីការជំរុញបង្កើតការងារ និងមុខរបរនៅជនបទ ទទួលបានថវិកាចំនួន ១៨០,៥០ លានរៀល ក្រោយវិចារណកម្មមាននៅសល់ថវិកាចំនួន ១១៣,១០ លានរៀល អនុវត្តបាន ២៨,១ លានរៀល ស្មើនឹង ២៥% ដោយបានបង្កើត និងគាំទ្រសហគមន៍សន្សំប្រាក់បាន ១វគ្គ នៅខេត្តកំពង់ចាម។ បណ្តុះបណ្តាលភាពជាសហគ្រិន ៣លើក នៅខេត្តតាកែវ ខេត្តកំពង់ឆ្នាំង និងខេត្តសៀមរាប សម្រេចបាន ១ លើក ស្មើនឹង ៣៣%។

អនុកម្មវិធីទី២ នៃកម្មវិធីទី៣ ស្តីពីការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅជនបទ ទទួលបានថវិកា ៣៤២,១ លានរៀល ក្រោយវិចារណកម្មនៅសល់ចំនួន ២២៣,៩ លានរៀល អនុវត្តបានចំនួន ១៧,៧ លានរៀល ស្មើនឹង ៨% ដោយបានរៀបចំសាងសង់គ្រឹះផ្សារជនបទមួយកន្លែងនៅខេត្តបាត់ដំបង, សិក្ខាសាលាបូកសរុបឥណទានប្រចាំឆ្នាំ ១លើក នៅខេត្តសៀមរាប សម្រេចបានបាន ១០០%, ចុះត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងឥណទាន ៥លើកសម្រេចបាន ១០០%។

អនុកម្មវិធីទី៣ នៃកម្មវិធីទី៣ ស្តីពីការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញអាជីពបានទទួលថវិកា ចំនួន ១០៣៩,៦ លានរៀល ក្រោយវិចារណកម្មនៅសល់ចំនួន ៧៣៦,១ លានរៀល ពុំបានអនុវត្ត។ ក្រសួងបានធ្វើការបណ្តុះបណ្តាលមានសិក្ខាកាមសរុបចំនួន ១២៧ នាក់ (ស្រី ២៧នាក់) ដែលក្នុងនោះការបណ្តុះបណ្តាល ក្នុងប្រទេសសរុបចំនួន ១២៦ នាក់ (ស្រី ២៦នាក់) និងការបណ្តុះបណ្តាលក្រៅប្រទេសសរុប ០១នាក់ (ស្រី) និងបានចូលរួមក្នុងសិក្ខាសាលានានានៅក្នុងប្រទេស សរុបសិក្ខាកាមចំនួន ៣៩១នាក់ ស្រី ៦៨ នាក់។ សរុបជារួមមន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាទាំងក្នុងប្រទេស និងក្រៅប្រទេស សរុបទាំងអស់ចំនួន ៥១៨ នាក់ (ស្រី ៩៥នាក់) ក្នុងនោះមានអ្នកទៅសិក្សានៅប្រទេសជប៉ុនចំនួន ០១នាក់ តាមរយៈកម្មវិធីរបស់ (JDS) ឆ្នាំ២០២០។ ការបណ្តុះបណ្តាលជំនាញនៅមជ្ឈមណ្ឌលបណ្តុះបណ្តាល ជំនាញមូលដ្ឋានក្នុងឆ្នាំ២០២១ អនុវត្តបានតែ ៦ខេត្តប៉ុណ្ណោះក្នុងចំណោម ១៣ខេត្ត។ ខេត្តទាំង ៦នោះមាន ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តពោធិ៍សាត់ និងខេត្តកំពត ដោយមានសិក្ខាកាមសរុប

បានចំនួន ៥៤០ (ស្រី១១៦នាក់)។ បើធៀបនឹងឆ្នាំ២០២០ ដែលមានសិក្ខាកាមសរុប ២ ៣៩៨ នាក់ (ស្រី ១ ១៧៤ នាក់) ឃើញថា សិក្ខាកាមមានការថយចុះសរុបចំនួន ១ ៨៥៥ នាក់ ស្មើនឹង ៧៧,៤៩%។

អនុកម្មវិធីទី៤ នៃកម្មវិធីទី៣ ស្តីពីការជំរុញការអភិវឌ្ឍន៍ចម្រុះសម្រាប់សហគមន៍ជនបទទទួលបានថវិកា ចំនួន ១ ១៨៩,៦ លានរៀល ក្រោយវិចារណកម្មនៅសល់ ៨៥៧,៣ លានរៀល ពុំបានអនុវត្ត។ ដោយឡែក មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចំនួន ០៦ ខេត្ត រួមមាន ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តព្រះវិហារ និងខេត្តរតនគិរី បានធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាព គ.អ.ភ ស្តីពីតួនាទី និងភារកិច្ច គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ និងសញ្ញាណចលនាភូមិថ្មី បានចំនួន ៣២ វគ្គ មកពី ២៤១ ភូមិ ដែលមានសិក្ខាកាមសរុប ៨៥៤ នាក់ (ស្រី ៣០២ នាក់)។ ធ្វើបច្ចុប្បន្នភាព គ.អ.ភ ក្នុងឆ្នាំ ២០២១ នេះ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត បានធ្វើបច្ចុប្បន្នភាពបានចំនួន ៨៩១ ភូមិ ៩៨ ឃុំ ៤១ ស្រុក ហើយមានសមាជិក គ.អ.ភ សរុបចំនួន ៦ ៩៣៧ នាក់ (ស្រី ១ ៧០៥ នាក់) ក្នុងនោះ ភូមិមានសកម្មភាពចំនួន ៥៣៣ ភូមិ, ភូមិអសកម្មភាពចំនួន ១៤៣ ភូមិ, ភូមិមានអង្គការគាំទ្រចំនួន ១៤ ភូមិ។ ការផ្តល់ជូននូវ ពូជរុក្ខជាតិ ពូជសត្វ និងស្រះចិញ្ចឹមត្រីជាដើម។ ជាលទ្ធផលក្នុងឆ្នាំ ២០២១ នាយកដ្ឋានបានគាំទ្រសកម្មភាពអភិឌ្ឍន៍ ភូមិ ចម្រុះរួមមានកូនឈើហូបផ្លែ ពូជសត្វ និងស្រះគ្រួសារ លើភូមិគោលដៅចំនួន ០៥ ភូមិ នៃខេត្តចំនួន ០៥ ខេត្ត។ ផ្តល់ពូជបន្លែចម្រុះ និងសម្ភារធ្វើរោងជីកំប៉ុស្តិ៍បានចំនួន ០៤ ខេត្ត។

អនុកម្មវិធីទី៥ នៃកម្មវិធីទី៣ ស្តីពីអភិវឌ្ឍន៍និងអភិរក្សជនជាតិដើមភាគតិចទទួលបានថវិកា ចំនួន ១៩០,៨ លានរៀល ពុំបានអនុវត្ត។ បន្តនីតិវិធីរៀបចំរបាយការណ៍ជូនដាក់ដឹកនាំដើម្បីទទួលស្គាល់អត្តសញ្ញាណក្នុងឆ្នាំ២០២១។ ចូលរួមកិច្ចប្រជុំស្តីពីការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចកួយ ចំនួន ០២ភូមិ នៅភូមិមន និងភូមិទាល់ ឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ ចូលរួមកិច្ចប្រជុំស្តីពីការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចកួយ ចំនួន ០២ភូមិ នៅភូមិស្រែណូយ និងភូមិរលំរុនថ្មី ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប។ ចូលរួមកិច្ចប្រជុំស្តីពី ការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចកួយ ចំនួន ២ភូមិ នៅភូមិជ្រាប់ចាស់ និងភូមិជ្រាប់ថ្មី ឃុំជប់វ៉ារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ក្រុមការងារនាយកដ្ឋានបានរៀបចំ ចែកម៉ាស់ អាកុល និងសាប៊ូ ជូនដល់ជនជាតិដើមភាគតិចដែលបានចូលរួម ចំពោះសមាសភាពចូលរួម មានតំណាងមន្ទីរអភិវឌ្ឍន៍ជនបទ អង្គការ NGO Forum សាលាខេត្ត សាលាក្រុង សាលាឃុំ និងអាជ្ញាធរ។ ចូលរួមកិច្ចប្រជុំស្តីពីការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចគួយ ចំនួន ២ភូមិ នៅភូមិតាម៉ាន និងភូមិថ្មី សង្កាត់កូនគ្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ សមាសភាពចូលរួម មានតំណាងមន្ទីរអភិវឌ្ឍន៍ជនបទ អង្គការ NGO Forum សាលាខេត្ត សាលាក្រុង សាលាឃុំ និងជនជាតិដើមភាគតិច។ ចូលរួមកិច្ចប្រជុំស្តីពី ការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចស្អូច ចំនួន ១ភូមិ នៅភូមិសំរុងលើ ឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ចូលរួមកិច្ចប្រជុំស្តីពី ការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចព័រ និងជង ចំនួន ០២ភូមិ នៅភូមិតាដែស និងភូមិអូព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ចូលរួមពិធីប្រកាសសុពលភាព និងអនុម័តសេចក្តីព្រាងបទបញ្ជាផ្ទៃ

ក្នុងសហគមន៍ជនជាតិដើមភាគតិចការ៉ែត ចំនួន ២ភូមិ ក្នុងការប្រើប្រាស់ចាត់ចែង ការគ្រប់គ្រងតាមបែបទំនៀមទម្លាប់ប្រពៃណីដូនតារបស់ពួកគាត់ នៅភូមិគិរីបាសលើ និងភូមិគិរីបាសក្រោម ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។

អនុកម្មវិធីទី៦ នៃកម្មវិធីទី៣ ស្តីពីការលើកកម្ពស់កម្រិតជីវភាពរស់នៅតាមជនបទ ដោយមន្ទីរជំនាញ ២៥ ទទួលបានថវិកាសរុប ៦១៨,៩ លានរៀល និងអនុវត្តបានចំនួន ៤២៣,១០ លានរៀល ស្មើនឹង ៦៨% ដោយសម្រេចបានជម្រុញបង្កើតការកែច្នៃផលិតផលសហគមន៍ជនបទបាន ៣លើក នៅឃុំបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ។ ស្វែងរកនិងទំនាក់ទំនងទីផ្សារជូនផលិតករសហគមន៍បាន ២លើក នៅខណ្ឌដង្កោ និងខណ្ឌកំបូល រាជធានីភ្នំពេញ។ ផ្សព្វផ្សាយគាំទ្រ ការងារវេណទាននៅសហគមន៍ជនបទបាន ៣៥៣ លើក។ ជំរុញមហាជនចូលរួមបង្កើតជំនាញអាជីពផ្ទាល់ខ្លួនបាន ១៧ លើក។ រៀបចំកម្មវិធីបណ្តុះបណ្តាល គ្រូបង្គោល (ToT) បាន ៥ វគ្គ។ ចុះពង្រឹងសមត្ថភាពគណៈកម្មការអភិវឌ្ឍន៍ភូមិបាន ១៧៨ វគ្គ មានអ្នកចូលរួម ៣៩៣នាក់។ ចុះស្រង់ទិន្នន័យ ដំបូងអំពីជីវិតរបស់ជនជាតិដើមភាគតិចបាន ៨ លើក។ ធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ សហគមន៍ជនជាតិដើមភាគតិច ១៧ ភូមិ។ ផ្សព្វផ្សាយគោលនយោបាយជនជាតិដើមភាគតិច បាន២១វគ្គ។

### ខ-គម្រោងហិរញ្ញប្បទានថវិកាដៃគូអភិវឌ្ឍន៍

**ទី១.** គម្រោងគាំទ្រនិរន្តរភាពហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីទីផ្សារកសិករ និងពាណិជ្ជូបនីយកម្មកសិកម្ម (SAAMBAT) ជាមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) ធនាគារវិនិយោគអឺរ៉ុប (EIB) និងសហគមន៍អឺរ៉ុប (EU) ដើម្បីអនុវត្តគម្រោងគាំទ្រនិរន្តរភាពហេដ្ឋារចនាសម្ព័ន្ធជនបទដើម្បីទីផ្សារកសិករ និងពាណិជ្ជូបនីយកម្មកសិកម្ម ហៅកាត់ថាគម្រោង SAAMBAT។ ថវិកាការប៉ាន់ប្រមាណគម្រោងសរុបមានថវិកាចំនួន ១៦២,៧៩ លានដុល្លារអាមេរិក។ គម្រោងមានគោលបំណងបង្កើននិរន្តរភាពនូវផលិតកម្មរបស់គ្រួសារ យុវជន ស្ត្រី និងក្រុមងាយរងគ្រោះដ៏ទៃទៀតនៅតាមតំបន់ជនបទ ព្រមទាំងគាំទ្រដល់សហគ្រាស និងសេដ្ឋកិច្ចជនបទសម្រាប់ការងារ និងការបង្កើតប្រាក់ចំណូល តាមរយៈការធ្វើអន្តរាគមន៍វិនិយោគហេដ្ឋារចនាសម្ព័ន្ធជនបទ, ការពង្រឹងសមត្ថភាពសម្រាប់ការគ្រប់គ្រងធនធាន, ពង្រឹងជំនាញ និងភាពជាសហគ្រិនសម្រាប់យុវជន និងគ្រួសារដែលក្រីក្រ និងងាយរងគ្រោះ, បង្កើនការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅក្នុងសេដ្ឋកិច្ចជនបទ, វិសមភាពយេនឌ័រ, រៀបចំបណ្តាញ និងភ្ជាប់ខ្សែច្រវ៉ាក់បញ្ចូលគ្នា (AIMS និង ASPIRE) ។ ជាលទ្ធផលចូលរួមដោះស្រាយបង្កើនផលិតភាព នៃពលកម្មកសិកម្ម នៅចំពោះមុខកង្វះខាតពលកម្មនៅជនបទ ដូចជា បង្កើនឱកាសទទួលបាននូវជំនាញ បច្ចេកវិទ្យា និងជំនាញប៉ិនប្រសប់ដ៏ទៃទៀតទទួលបានជាតុចូលសម្រាប់ការដាំដុះ ផលិតផល កសិកម្ម និងឱកាសទីផ្សារហិរញ្ញវត្ថុ និងសកម្មភាពនានានៅក្នុងខ្សែច្រវ៉ាក់តម្លៃកសិកម្ម។ បង្កើនសេវាកម្ម ឬឱកាសមានការងារធ្វើនៅតាមជនបទ ក្រៅពីការធ្វើស្រែចម្ការ។ ដោះស្រាយហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងពង្រឹងនិងលើកតម្កើងសមភាពយេនឌ័រ។

### ២.៤.កម្មវិធីទី៤៖ ពង្រឹងសេវាគាំទ្ររដ្ឋបាលនិងកិច្ចការទូទៅ

ទទួលបានថវិកាសរុបចំនួន ៥១ ៧៤១,៣០ លានរៀល ក្រោយវិចារណកម្មនៅសល់ថវិកា

៤៩ ០១៥,៧៧ លានរៀល អនុវត្តបានចំនួន ៤៥ ៨២៣ លានរៀល ស្មើនឹង ៩៤% និងសម្រេចគោលដៅបាន ៦៦,៣%។

**ក-គម្រោងហិរញ្ញប្បទានថវិកាជាតិ**

អនុកម្មវិធីទី១ នៃកម្មវិធីទី៤ ស្តីពីការពង្រឹងគុណភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងផែនការអភិវឌ្ឍន៍ជនបទ បានទទួលថវិកាចំនួន៥៩៥,២ លានរៀល ក្រោវិចារណកម្មនៅសល់ចំនួន ៤០៥,៣ លានរៀល អនុវត្តបានចំនួន ១៧១,៩២ លានរៀល ស្មើនឹង៤២% ដោយសម្រេចបាន ចុះពង្រឹងរៀបចំផែនការយុទ្ធសាស្ត្រ តាមមន្ទីររាជធានី/ខេត្ត ទាំង ២៥ បាន ១០០%។ រៀបចំសិក្ខាសាលាតាមអនឡាញស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាការពិនិត្យលើវឌ្ឍនភាព និងគុណភាពសិក្សាពីការកំណត់តំបន់ជនបទ ស្ថានភាពជនបទ និងប្រឹក្សាអំពីគោលបំណងសូចនាករ និងគោលដៅបាន ១២លើក នៃគម្រោង ១៤ លើក ស្មើនឹង ៨៤%។ រៀបចំសិក្ខាសាលាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ តាមអនឡាញបានចំនួន ២ លើក។ រៀបចំសិក្ខាសាលាស្តីពីការរៀបចំថវិកាកម្មវិធីចំនួន ៣ លើក។ ប្រជុំចរចារកញ្ចប់ថវិកាប្រចាំឆ្នាំ២០២២ ចំនួន ២លើក តាមអនឡាញ។ ចុះតាមដានការអនុវត្តកិច្ចព្រមព្រៀងជាមួយអង្គការមិនមែនរដ្ឋាភិបាល បាន ៨ខេត្ត ស្មើនឹង ៥៦%។ រៀបចំសិក្ខាសាលាបូកសរុប និងវាយតម្លៃលទ្ធផលប្រចាំឆ្នាំនៃកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល បាន ១លើក និងបូកសរុប និងវាយតម្លៃការអនុវត្តផែនការថវិកាកម្មវិធីបាន ១ លើក ស្មើនឹង ១០០%។ ចុះប្រមូលទិន្នន័យ តាមរាជធានីខេត្តចំនួន ២០ ស្មើនឹង ១០០%នៃគោលដៅ ។ ចូលរួមសិក្ខាសាលាស្តីពីការកំណត់អាទិភាព និងចក្ខុវិស័យសហគមន៍ សង្គម វប្បធម៌ អាស៊ាន នៅពេលដែលប្រទេសកម្ពុជាក្លាយជាប្រធានកិច្ចប្រជុំ អាស៊ាន និងកិច្ចប្រជុំផ្សេងៗទៀត នៅឆ្នាំ២០២២ តាមប្រព័ន្ធ Zoom ដោយមានប្រទេសប្រុយណេ ជាអ្នកសម្របសម្រួល។ ចូលរួមប្រជុំក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីការរៀបចំផែនការសកម្មភាពក្រសួងដំណាក់កាល ៣+២ (MAP3+2) និងគោលការណ៍ណែនាំស្តីពីផែនការសកម្មភាពគន្លឹះ ឆ្នាំ២០២២។ ចូលរួមផ្តល់យោបល់លើឯកសារសេចក្តីប្រកាសរួមកិច្ចប្រជុំកំពូលមេគង្គ-សាធារណរដ្ឋកូរ៉េ និងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០២១-២០២៥ នៃកិច្ច សហប្រតិបត្តិការ មេគង្គ-សាធារណរដ្ឋកូរ៉េ។ ចូលរួមកិច្ចប្រជុំប្រមូលទិន្នន័យពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវនគរូបនីយកម្ម ការធ្វើទេសន្តប្រវេសន៍ និងការអភិវឌ្ឍន៍ប្រកបដោយបរិយាប័ន្ននៅទីក្រុង និងជនបទ ក្នុងសហគមន៍អាស៊ានរៀបចំដោយអគ្គលេខាធិការអាស៊ាន។ ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេស មេគង្គ-ឡានឆាង លើកទី៥ ជាមួយភាគីសាធារណរដ្ឋប្រជាមានិតចិនពីការកាត់បន្ថយភាពក្រីក្រក្នុងតំបន់អាស៊ានតាមប្រព័ន្ធអនឡាញ។ ចូលរួមប្រជុំវេទិកាអាស៊ានក្រោមប្រធានបទ ជំរុញម៉ាក្រូសហគ្រាសខ្នាតតូច និងមធ្យម ពិភាក្សាប្រធានបទសហគ្រិនជនបទ កសាងភាពស៊ាំក្រោយកូវីដ-១៩ រៀបចំដោយប្រទេសប្រ៊ុយណេដារុយសាឡឹម តាមប្រព័ន្ធអនឡាញ។ ចូលរួមប្រជុំអាស៊ានស្តីពីការអភិវឌ្ឍជនបទ និងការកាត់បន្ថយភាពក្រីក្រ ដែលរៀបចំដោយប្រទេសហ្វីលីពីន តាមប្រព័ន្ធអនឡាញ។ ចូលរួមកិច្ចប្រជុំកំពូលអាស៊ានបូក ចិន ជប៉ុន កូរ៉េខាងត្បូងស្តីពីអភិវឌ្ឍន៍ជនបទ និងកាត់បន្ថយភាពក្រីក្រ តាមប្រព័ន្ធអនឡាញ។ ចូលរួមប្រជុំជាមួយ ADB ក្នុងកម្មវិធីពង្រឹងការគ្រប់គ្រង

ហិរញ្ញវត្ថុសាធារណៈសម្រាប់អនុគម្រោងទី២ តាមប្រព័ន្ធអនឡាញ។ ចូលរួមប្រជុំជាមួយ IMF ពិភាក្សាពីការប្រើប្រាស់ប្រព័ន្ធ FMIS សម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធអនឡាញ។ ចូលរួមប្រជុំជាមួយក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីត្រួតពិនិត្យការអនុវត្តគម្រោងជាមួយ ADB សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងយេនឌ័រ។

អនុកម្មវិធីទី២ នៃកម្មវិធីទី៤ ស្តីពីការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាកម្មវិធីទទួលបានថវិកា ចំនួន ៥១៥ លានរៀល ក្រោយវិចារណកម្មនៅសល់ចំនួន ៣៩១ លានរៀល អនុវត្តបានចំនួន ៣៧១,៤៥ លានរៀល ស្មើនឹង៩៥% ដោយសម្រេចបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តថវិកាកម្មវិធី ០១វគ្គ នៅខេត្តសៀមរាប, ចុះផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌទ្រព្យរដ្ឋ ២៥ រាជធានី ខេត្ត សម្រេចបាន ១០០%, សិក្ខាសាលាពង្រឹងសមត្ថភាពគ្រប់គ្រងបញ្ជីសារពើភណ្ឌ ០១វគ្គ នៅខេត្តបាត់ដំបង សម្រេចបាន១០០%, សិក្ខាសាលាពង្រឹងការប្រើប្រាស់ប្រព័ន្ធ FMIS បាន ១វគ្គ សម្រេចបាន ១០០%។

អនុកម្មវិធីទី៣ នៃកម្មវិធីទី៤ ស្តីពីការបង្កើនប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង ទទួលបានថវិកា ១៨៨,៥ លានរៀល ក្រោយវិចារណកម្មនៅសល់ចំនួន ១០៧,៤ លានរៀល អនុវត្តបានចំនួន ៨៤លានរៀលស្មើនឹង ៧៨% ដោយបានគ្រោងរៀបចំសិក្ខាសាលាផ្សព្វផ្សាយសវនកម្មផ្ទៃក្នុងបាន ២លើក នៅខេត្តត្បូងឃ្មុំ និងខេត្តរតនគិរី សម្រេចបាន ១លើក ស្មើនឹង ៥០%។ ប្រតិបត្តិការសវនកម្មផ្ទៃក្នុង លើ ២៧អង្គភាព នៅនាយកដ្ឋាន ២ និង២៥ ខេត្ត សម្រេចបាន ៧០%។ ចុះតាមដានអនុសាសន៍សវនកម្ម ០២ ខេត្ត នៅខេត្តកំពង់ធំ និងខេត្តកំពង់ស្ពឺ សម្រេចបាន១០០% នៃគោលដៅ។ ចុះធ្វើអធិការកិច្ច ខេត្តកំពង់ធំ ខេត្តកំពង់ស្ពឺ ខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ ចំនួន ២វគ្គសម្រេចបាន ៥០%។ ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងចំណូល-ចំណាយ និងការប្រើប្រាស់ថវិការបស់រដ្ឋការិយបរិច្ឆេទ ឆ្នាំ២០២០ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ២០ខេត្ត រួមមាន៖ ខេត្តបាត់ដំបង ខេត្តកំពត ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តត្បូងឃ្មុំ ខេត្តកែប ខេត្តពោធិ៍សាត់ ខេត្តកំពង់ចាម ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។

អនុកម្មវិធីទី៤ នៃកម្មវិធីទី៤ ស្តីពីការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងរដ្ឋបាល និងយេនឌ័រ ទទួលបានថវិកា ១៨១ លានរៀល ក្រោយវិចារណកម្មនៅសល់ចំនួន ១១៦,៥លានរៀល អនុវត្តបាន ១១,៨ លានរៀល ស្មើនឹង ១០,១៣% ដោយបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយការលើកកម្ពស់សិទ្ធិជនពិការពិភពលោក ១វគ្គ សម្រេច បាន១៧% នៃគោលដៅ។ ក្នុងឆ្នាំ២០២១ នេះមន្ត្រីរាជការសរុបរបស់ក្រសួងមានចំនួន១ ៦១២ រូប (ស្រី ៤២២ រូប) មន្ត្រីគ្មានក្របខណ្ឌ និងមន្ត្រីមិនស្ថិតក្នុងក្របខណ្ឌរបស់ក្រសួង ចំនួន ១២២ រូប (ស្រី ១៨ រូប) និងមន្ត្រីរាជការក្នុងក្របខណ្ឌរបស់ក្រសួងចំនួន ១ ៤៨៩ រូប (ស្រី ៤០៤ រូប) ក្នុងនោះថ្នាក់កណ្តាលមានចំនួន ៦២០ រូប (ស្រី ១៩០ រូប) និងថ្នាក់មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី ខេត្ត ចំនួន ៨៦៩ រូប (ស្រី ២១៤ រូប)។ ដោយមានការគាំទ្រតាមរយៈកម្មវិធី CAVAC ក្រុមការងារយេនឌ័របានបន្តចុះផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៩-២០២៣ និងបណ្តុះបណ្តាល ស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាច

ផ្នែកសេដ្ឋកិច្ចដល់ស្ត្រី នៅតាមមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងបន្តការផ្សព្វផ្សាយដល់សហគមន៍បន្ថែមទៀត នៅមន្ទីរអភិវឌ្ឍន៍ជនបទ និងនៅសហគមន៍ក្នុងខេត្តព្រៃវែង ខេត្តតាកែវ ខេត្តកំពត និងខេត្តព្រះសីហនុ។

អនុកម្មវិធីទី៥ នៃកម្មវិធីទី៤ ស្តីពីសេវាគាំទ្រគោលនយោបាយ ទទួលបានថវិកាសរុបចំនួន ២២ ៩៧៦,៤ លានរៀល ក្រោយវិចារណកម្មនៅសល់ ២០ ៧១០,៥ លានរៀល អនុវត្តបាន ២០ ៦២៥,៣០ លានរៀល ស្មើនឹង ១០០% ដោយបានបើកបៀវត្សមន្ត្រីរាជការ ប្រាក់បេសកម្ម ប្រេងឥន្ធនៈ និងសេវាគាំទ្រដទៃទៀត ១២ ខែ សម្រេចបាន១០០%។ ជួសជុលអាគារ នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ និងទីស្តីការក្រសួងបំពាក់ម៉ាស៊ីនត្រជាក់ ផ្គត់ផ្គង់បរិក្ខាបច្ចេកវិទ្យាព័ត៌មានវិទ្យា នៅទីស្តីការក្រសួង សម្រេចបាន ១០០%។ លេខាធិការដ្ឋានក្រុមជំនួយការចុះមូលដ្ឋាន របស់ក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលរបាយការណ៍ពីមន្ទីរអភិវឌ្ឍន៍ជនបទ ២៥ រាជធានី ខេត្ត មានសំណើ ចំនួន ១២ករណី តាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ក្នុងនោះបានដោះស្រាយរួចរាល់ចំនួន ០៦ ករណី និងមិនទាន់បានដោះស្រាយចំនួន ០៦ ករណី។

អនុកម្មវិធីទី៧ នៃកម្មវិធីទី៤ ស្តីពីការពង្រឹងសមត្ថភាព និងសេវាគាំទ្រដោយមន្ទីរជំនាញទាំង ២៥ រាជធានី ខេត្ត ដោយទទួលបានថវិកាចំនួន ២៧ ២៨៥,២០ លានរៀល អនុវត្តចំណាយបាន ២៤ ៩៤១ លានរៀល ស្មើនឹង៩១% ដោយសម្រេចបានពង្រឹងគុណភាពរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកា កម្មវិធីបានចំនួន ០៥ លើក។ តាមដាន និងវាយតម្លៃការអនុវត្តថវិកាឆ្ពោះទៅរៀបចំរបាយការណ៍សមិទ្ធកម្ម ចំនួន៤៤ លើក។ ពង្រឹងសមត្ថភាពគ្រប់គ្រងសារពើភណ្ឌចំនួន ១២លើក។ ពង្រឹងប្រតិបត្តិការផែនការអង្គភាពថវិកាចំនួន ១១៨លើក។ ពង្រឹងរដ្ឋបាលកិច្ចការទូទៅ ៩៣លើក និងពង្រឹងការគ្រប់គ្រង ទិន្នន័យ បញ្ជីទ្រព្យរដ្ឋចំនួន ១២០លើក។

### ២.៥.បញ្ហាប្រឈមសម្រាប់ដោះស្រាយឆ្នាំ២០២២ និងឆ្នាំ២០២៣

**បញ្ហាប្រឈម៖**

ការសម្រេចបាននូវសមិទ្ធផលជាច្រើនខាងលើ បានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច កាត់បន្ថយបានភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនជនបទ បានថែមមួយកម្រិតទៀត។ ទន្ទឹមនឹងនេះក្រសួងអភិវឌ្ឍន៍ជនបទ ក៏បាននិងកំពុងបន្តជួបប្រទះនូវបណ្តាការប្រឈម មួយចំនួនដែលទាមទារឱ្យមានការដោះស្រាយជាប្រព័ន្ធ និងទាន់ពេលវេលាប្រកបដោយ ប្រសិទ្ធភាព និងការទទួលខុសត្រូវដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាជនជនបទ និងតម្រូវការក្នុងការអភិវឌ្ឍនៅតំបន់ជនបទទាំងមូល។ បណ្តាការប្រឈមសំខាន់ៗដែលបាននិងកំពុងជួបប្រទះរួមមាន៖ (១).ជំងឺកូវីដ-១៩ នៅតែបន្តសកម្មភាពប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនក្នុងសហគមន៍ជនបទ (២).ការប្រែប្រួលអាកាសធាតុជាបញ្ហាសកល ដែលរងការប្រឈមប៉ះពាល់ដោយផ្ទាល់លើការងារអភិវឌ្ឍន៍ជនបទគ្រប់ផ្នែកដែលទាមទារនូវនវានុវត្តន៍ និងបានបង្កើនការចំណាយថវិកាខ្ពស់ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ (៣).កង្វះថវិកាសម្រាប់គាំទ្រការបណ្តុះបណ្តាលជំនាញមូលដ្ឋាន សម្រាប់ធានានិរន្តរភាពការងារ និងប្រាក់ចំណូលរបស់ប្រជាជន (៤).ការចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មដែលក្រសួងសម្រេចបាន នៅពុំទាន់បង្កើតក្រុមការងារបាន

នៅឡើយ (៥).ការងារថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍នៅមានកម្រិត បើធៀបទៅនឹងប្រវែងផ្លូវជនបទសរុប (៦).ការផ្គត់ផ្គង់វត្ថុធាតុដើមដែលមានគុណភាព សម្រាប់ការសាងសង់ផ្លូវជនបទ មានការថយចុះជាលំដាប់ ដែលជះឥទ្ធិពលដល់គុណភាពផ្លូវជនបទ (៧).ខ្វះវិធានការទប់ស្កាត់យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ (៨).ពិបាករកទីតាំងសម្រាប់ជីកស្រះ និងខួងអណ្តូងសម្រាប់ប្រើប្រាស់ជាសាធារណៈ (៩).គណៈកម្មការអភិវឌ្ឍន៍ភូមិពុំមានស្នាក់ការសម្រាប់ធ្វើការងារ។

**ការអន្តរាគមន៍លើបញ្ហាប្រឈម**

ឆ្នាំ២០២២ និងឆ្នាំ២០២៣ ថ្វីត្បិតនៅមានការរាតត្បាតជំងឺកូវីដ-១៩ តែសម្រាប់ប្រទេសកម្ពុជា រាជរដ្ឋាភិបាលបានទទួលជោគជ័យយ៉ាងធំធេងក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការរាតត្បាតនៃជំងឺនេះបានល្អ និងបានប្រកាសបើកប្រទេសឲ្យដំណើរការសេដ្ឋកិច្ចឡើងវិញ ធានាបានការបន្តលើកកម្រិតជីវភាពរស់នៅរបស់ប្រជាជនឡើងវិញ ក្រោយកូវីដ១៩ ក្នុងនោះរាជរដ្ឋាភិបាលក៏មានផែនការស្តារសេដ្ឋកិច្ចតាមរយៈ **"ការកែលម្អផែនការថវិកាសម្រាប់គាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុកសម្រាប់ឆ្នាំ២០២២"** ដែលដាក់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រសួងអភិវឌ្ឍន៍ជនបទបានត្រៀមលក្ខណៈ និងបានកំណត់វិធានការអន្តរគមន៍សម្រាប់ឆ្នាំ២០២២ និងឆ្នាំ២០២៣ ដោយប្រើប្រាស់ ធនធាន ថវិកាជាតិ និងថវិកាហិរញ្ញប្បទានក្រៅប្រទេសដូចខាងក្រោម៖

ឆ្នាំ២០២២នេះ ក្រសួងនៅបន្តការអនុវត្តតាមគោលនយោបាយចាស់ និងកម្មវិធីចំនួន៤ ក្នុងនោះបន្តអនុកម្មវិធី, ចង្កោមសកម្មភាព និងសកម្មភាពមួយចំនួនត្រូវបានកែសម្រួលស្របតាមបរិបទថ្មីៗ ស្របនឹងគោលដៅដែលបានកំណត់រួចមកហើយ។ ថវិកាឆ្នាំ២០២២ គឺជាយន្តការដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវបញ្ហា ការប្រឈមនានាដែលបានកើតនិងបម្រុងនឹងកើតនៅតំបន់ជនបទ ដើម្បីរក្សាជីវភាពរស់នៅឲ្យមានស្ថេរភាព សុខភាពប្រចាំថ្ងៃមាំមួនជៀសផុតពីជំងឺផ្សេងៗពិសេសជំងឺកូវីដ១៩ ដែលកំពុងញាំញីសុខភាពប្រជាជននាពេលបច្ចុប្បន្ន និងកំណត់គោលដៅស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិប្បត្តិនៃជំងឺឆ្លងនេះ។

ដើម្បីធានាបានគុណភាពនៃជីវិតល្អប្រសើរ ចាំបាច់ត្រូវបង្កើនស្ថិរភាពនៃប្រាក់ចំណូលតាមគ្រួសារនីមួយៗឲ្យបាន ដែលប្រការនេះប្រជាជនម្នាក់ៗត្រូវតែខិតខំពង្រឹងដោយខ្លួនឯង ហើយរដ្ឋាភិបាលជាអ្នកជំរុញគាំទ្រ និងឧបត្ថម្ភតាមគ្រប់មធ្យោបាយដើម្បីសម្រេចបាន គោលបំណងគោលនយោបាយខាងលើ។ ក្នុងន័យនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានបន្តដាក់ចេញកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងកម្មវិធីចំនួនបួនដើម្បីគាំទ្រគោលនយោបាយខាងលើដូចខាងក្រោម៖

**កម្មវិធីទី១ ៖ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

**កម្មវិធីទី២ ៖ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

**កម្មវិធីទី៣ ៖ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

**កម្មវិធីទី៤ ៖ ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ**

ដោយអនុលោមតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៩-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ បានចែងពីសូចនាករគោលដៅសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាកម្មវិធី។ ក្នុងឆ្នាំ ២០២២ ក្រសួងបានកំណត់លទ្ធផលក្នុងឆ្នាំ ដូចខាងក្រោម៖

- ការស្តារនិងសាងសង់ផ្លូវជនបទលើប្រវែងផ្លូវសរុប ៣ ៦៣៦ គ.ម ដោយសម្រេចឲ្យបានដល់ ៣៩ ៨១៦ គ.ម
- កែលម្អផ្លូវជនបទទៅជាផ្លូវក្រាលកៅស៊ូពីរជាន់ឬបេតុងដើម្បីធន់នឹងការប្រែប្រួលអាកាសធាតុឲ្យបានប្រវែង ២០៧ គ.ម
- ការថែទាំផ្លូវជនបទជាលក្ខណៈខួប ប្រចាំ និងបន្ទាន់សរុបប្រវែង ១៥ ៤៦៣ គ.ម
- ភាគរយប្រជាជនជនបទទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អប្រកបដោយនិរន្តភាពដែលត្រូវសម្រេច ឲ្យបាន ៨៤% នៅទូទាំងតំបន់ជនបទ
- ភាគរយប្រជាជនជនបទទទួលបានសេវាអនាម័យដែលមានការកែលម្អប្រកបដោយនិរន្តភាពដែលត្រូវសម្រេចឲ្យបាន ៨៧% នៅទូទាំងតំបន់ជនបទ
- ខេត្តដែលបានបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល(ODF)បានដល់ ៤ ខេត្ត (១ខេត្តក្នុង១ឆ្នាំ)
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈចល័តឲ្យបាន ៥មណ្ឌល ក្នុងមួយឆ្នាំ
- ចំនួនប្រជាពលរដ្ឋដែលទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋាន ឲ្យបានដល់ ២៥ ០០០នាក់
- ចំនួនគ្រួសារដែលបានបង្កើតសហគ្រាសខ្នាតតូចថ្មីក្រោយបានទទួលការបណ្តុះបណ្តាលជំនាញមូលដ្ឋាន ឲ្យបានដល់ ៤៥០គ្រួសារ
- មន្ត្រីរាជការក្រសួងដែលទទួលបានការពង្រឹងសមត្ថភាពដល់ ៧០ម៉/នាក់
- ចំនួនសហគមន៍ជនជាតិដើមភាគតិចបានទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទឲ្យបានដល់ ១៨៣សហគមន៍ ។

## ៣. ទិសដៅការគោលនយោបាយអាទិភាព សម្រាប់រួមចំណែកអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាល និងអន្តរវិស័យក្នុងវិស័យអភិវឌ្ឍន៍ជនបទ ឆ្នាំ ២០២៣-២០២៥

ក្រសួងអភិវឌ្ឍន៍ជនបទ បន្តការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ៥ ឆ្នាំ២០១៩-២០២៣ ដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យដែលបានកំណត់ថា **"ការលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌"** ដោយរក្សាយុទ្ធសាស្ត្រ និងយុទ្ធវិធីចំនួន ០៤ ដូចខាងក្រោម៖

**យុទ្ធសាស្ត្រទី១ ៖ ស្តាបនាលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍នៅជនបទ** ដោយបង្កើនការស្តាបនា ជួសជុល លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គមនាគមន៍ និងសេវាសម្រាប់សាធារណៈជន ដូចជាផ្លូវជនបទ សំណង់សិល្បការ្យផ្សេងៗ ឲ្យមានភាពធន់នឹងការប្រើប្រាស់ទប់ទល់បានការ

ប្រែប្រួល អាកាសធាតុ ដើម្បីជានាដល់ការដឹកជញ្ជូន និងសេវាសាធារណៈផ្សេងៗទៀតនៅតំបន់ជនបទ ដើម្បីបង្កើនសក្តានុពលសេដ្ឋកិច្ច និងបម្រើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។

**យុទ្ធសាស្ត្រទី២ ៖ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់ប្រជាជននៅតាមសហគមន៍ជនបទ** ដែលផ្តោតសំខាន់លើការលើកកម្ពស់សុខភាព អនាម័យ ការអប់រំប្រជាជនយល់ដឹងពីការរស់នៅស្អាត ផឹកស្អាត ភូមិឃុំមាន បរិស្ថានរស់នៅស្អាត ភូមិឃុំមានសុវត្ថិភាព សំដៅជំរុញលក្ខខណ្ឌនៃការរស់នៅតាមតំបន់ជនបទ ឲ្យបានល្អប្រសើរ តាមរបៀបរស់នៅបែបទំនើបនៅតំបន់ជនបទ (Rural Lifestyle Condition) ដោយមានសេវាទឹកស្អាត អនាម័យ គ្រប់គ្រាន់ ពិសេសបញ្ឈប់ការបន្ទោរបង់ ពាសវាលពាសកាលក្នុងសហគមន៍ជនបទ។

**យុទ្ធសាស្ត្រទី៣ ៖ ជំរុញពិពិតកម្មសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារនៅជនបទ** ដោយមានគោលបំណងរួមចំណែកក្នុងការចូលរួមដោះស្រាយបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន នៅជនបទដែលជាកត្តាសំខាន់បំផុតពុំអាចខ្វះបានក្នុងជីវភាពរស់នៅប្រចាំថ្ងៃ តាមរយៈការបង្កើនប្រាក់ចំណូលប្រចាំថ្ងៃរបស់ប្រជាជននៅជនបទ ដើម្បីរួមចំណែកជំរុញការកាត់បន្ថយភាពក្រីក្រនៅជនបទនៃប្រទេសកម្ពុជា។ ក្រសួងក៏មានគោលដៅបង្កើតផ្សារជនបទ, បង្កើតក្រុមសន្សំ, ផ្តល់ឥណទាន ដើម្បីបង្កើតមុខរបរ និងការងារតាមគ្រួសារ។ បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋានឲ្យបានកាន់តែច្រើនឡើងថែមទៀត ពិសេសមជ្ឈមណ្ឌលមូលដ្ឋានចល័តនៅតំបន់ជនបទដាច់ស្រយ៉ាល ដើម្បីបង្កិតសេវាផ្តល់ជំនាញមូលដ្ឋានកាន់តែទៅជិតភូមិ ឃុំ ស្រុករបស់ប្រជាជន ដែលបង្កលក្ខណៈឲ្យប្រជាជនមានលទ្ធភាពចូលរួមកាន់តែច្រើនឡើងៗ មកទទួលយកជំនាញមួយយ៉ាងតិចសម្រាប់យកទៅប្រកបរបរចិញ្ចឹមជីវិត ដែលទទួលបានប្រាក់ចំណូលខ្ពស់ជាងមុនតាមរយៈកម្មវិធីបំណិនជីវិត។

**យុទ្ធសាស្ត្រទី៤ ៖ អភិបាលកិច្ច ផែនការ ហិរញ្ញវត្ថុ និងកិច្ចការទូទៅក្នុងក្រសួង** ជាកម្មវិធីបង្កើតឡើងសម្រាប់ផ្តល់សេវាផ្សេងៗគាំទ្រដល់កម្មវិធីទាំង៣ ខាងលើឲ្យទទួលបានជោគជ័យ។ កម្មវិធីនេះមានគោលបំណងបង្កើនប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះសមិទ្ធកម្ម ក្នុងការប្រើប្រាស់ថវិកាឲ្យចំគោលដៅបម្រើដល់គោលបំណងគោលនយោបាយរបស់ក្រសួង ក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ។ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កែទម្រង់រដ្ឋបាលសាធារណៈ និងកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីនេះផងដែរ ដែលសំដៅដល់ការពង្រឹងសមត្ថភាពមន្ត្រី ក្នុងការអនុវត្តគម្រោងផែនការថវិកាកម្មវិធីប្រចាំឆ្នាំ ពិសេសការអនុវត្តយុទ្ធសាស្ត្រ កែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥ ឲ្យទទួលបានជោគជ័យ។

## ៣.១.ផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥

ដើម្បីសម្រេចបានទិសដៅជាយុទ្ធសាស្ត្រខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រថវិកាចំនួន ០៤ ដូចខាងក្រោម៖

- **ផែនការយុទ្ធសាស្ត្រទី១៖ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍**
- **ផែនការយុទ្ធសាស្ត្រទី២៖ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**
- **ផែនការយុទ្ធសាស្ត្រទី៣៖ ជំរុញពិពិតកម្មសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារនៅជនបទ**
- **ផែនការយុទ្ធសាស្ត្រទី៤៖ ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ**

### ៣.២. គោលបំណងគោលនយោបាយ

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយតាមវិស័យ ពិសេសគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឲ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់លក្ខខណ្ឌរស់នៅរបស់ប្រជាជនជនបទឲ្យបានល្អប្រសើរ ក្រសួងអភិវឌ្ឍន៍ជនបទ មានគោលបំណងគោលនយោបាយដូចខាងក្រោម៖

| **គោលបំណងគោលនយោបាយ** | **បម្រើឲ្យគោលដៅយុទ្ធសាស្ត្រណាមួយ និងវិធានការគោលនយោបាយអ្វីខ្លះរបស់រាជរដ្ឋាភិបាល** | **ស្ថិតក្នុងវិស័យណាមួយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៩-២០២៣** |
|---|---|---|
| លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌។ | យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចតុកោណទី៤ មុំទី១ ការលើកកម្ពស់កសិកម្ម និងការអភិវឌ្ឍជនបទ<br>ចតុកោណទី២ ការធ្វើពិពិធកម្មសេដ្ឋកិច្ច មុំទី១ ការកែលម្អប្រព័ន្ធឡជីស្ទីក ,លើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល<br>ចតុកោណទី៣ ការលើកស្ទួយវិស័យឯកជន និងការងារ<br>ចតុកោណទី១ ការអភិវឌ្ឍធនធានមនុស្ស។ | ហេដ្ឋារចនាសម្ព័ន្ធ ការតភ្ជាប់ផ្នែកដឹកជញ្ជូន បង្កើតការងារ សហគ្រាស និងមុខរបរ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ អភិវឌ្ឍន៍ធនធានមនុស្សពង្រឹង សមត្ថភាព។ |

### ៣.៤.ការរៀបចំកម្មវិធី

ផែនការយុទ្ធសាស្ត្រថវិកាទាំង៤ ខាងលើបានដំណើរការអនុវត្តបាន ៣ ឆ្នាំហើយ ដើម្បីសម្រេចគោលបំណងគោលនយោបាយក្រសួង ក៏ដូចជាគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជាដែរ។ ដើម្បីអនុវត្តយុទ្ធសាស្ត្រទាំង៤ ដូចបានរៀបរាប់ខាងលើឲ្យមានប្រសិទ្ធភាព ក្រសួងបានប្រែក្លាយយុទ្ធសាស្ត្រទាំងនេះទៅជាកម្មវិធីសម្រាប់យកទៅអនុវត្តជាក់ស្តែង ៖

**កម្មវិធីទី១ ៖ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍** មានគោលបំណង៖ បង្កើនការតភ្ជាប់បណ្ដាញផ្លូវជនបទប្រកបដោយគុណភាព ធុននឹងការប្រែប្រួល អាកាសធាតុ

**កម្មវិធីទី២ ៖ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ** មានគោលបំណង៖ លើកកម្ពស់គុណភាពនៃការរស់នៅប្រជាជនជនបទប្រកបដោយសុខមាលភាព

**កម្មវិធីទី៣ ៖ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ** មានគោលបំណង៖ លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនជនបទឲ្យបានល្អប្រសើរ

**កម្មវិធីទី៤ ៖ ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ** មានគោលបំណង៖ ពង្រឹងអភិបាលកិច្ច និងគណនេយ្យភាពនៃការអនុវត្តគោលនយោបាយ របស់ក្រសួង

## ៤. ការកំណត់ធនធាន

ផែនការយុទ្ធសាស្ត្រថវិកានេះ ត្រូវបានរៀបចំឡើងក្នុងបរិបទដែលពិភពលោកកំពុងជួបនឹងវិបត្តិនៃការរាតត្បាតជម្ងឺកូវីដ-១៩ ដែលកំពុងព្រួញប្រាននឲ្យមានវិបត្តិសេដ្ឋកិច្ចស្ទើរគ្រប់ប្រទេស។ ដើម្បីរួមចំណែកដល់ការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៩-២០២៣ ក្រសួងបានខិតខំកៀរគរកជំនួយពីគ្រប់ផ្នែក ដៃគូ និងវិស័យឯកជនសម្រាប់ជួយជំរុញវិស័យអភិវឌ្ឍន៍ជនបទឲ្យក្លាយជាឆ្អឹងខ្នងជួយជំរុញកំណើនសេដ្ឋកិច្ចនៅជនបទ តាមរយៈបង្កើតការងារបណ្ដុះបណ្ដាលជំនាញ បង្កើតផ្សារដោះដូរទំនិញសម្រាប់អាជីកម្មខ្នាតគ្រួសារ ដើម្បីបង្កើនប្រាក់ចំណូលតាមគ្រួសារនៅជនបទ។ ការលើកកម្ពស់គុណភាពជីវិត និងសុខុមាលភាពប្រជាជន នៅតែជាកត្តាចាំបាច់ សម្រាប់ទ្រទ្រង់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋជនបទតាមរយៈបង្កើនការផ្ដល់សេវាទឹកស្អាត អនាម័យនៅជនបទឲ្យបានល្អប្រសើរ។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចតាមរយៈតភ្ជាប់ពីជនបទមកកាន់ទីប្រជុំជន ដើម្បីដោះដូរពាណិជ្ជកម្ម សិស្សានុសិស្សអាចទៅសាលារៀនបានដោយស្រួល អ្នកជម្ងឺអាចទៅមន្ទីរពេទ្យបានទាន់ពេលវេលា និងអាចសង្គ្រោះជីវិតប្រជាពលរដ្ឋបាន។

ក្នុងដំណើរការអភិវឌ្ឍន៍ជនបទក្នុងរយៈពេល ៣ ឆ្នាំខាងមុខនេះ (ឆ្នាំ២០២៣-២០២៥) ក្រសួងត្រូវការធនធានសរុបចំនួន **១ ៩៦៨ ៩៦៥,៤២ លានរៀល** ក្នុងនោះចំណាយចរន្តត្រូវការចំនួន **៧០០ ១៥២,៨៧** លានរៀល (១០០ ៤៤១,៨០ លានរៀលជាបន្ទុកបុគ្គលិក ៥៩៩ ៧១១,០៧ លានរៀល បន្ទុកក្រៅបុគ្គលិក) និងថវិកាវិនិយោគសរុបចំនួន ១ ២៦៥ ៥៧២,៥៦ លានរៀល។ កម្មវិធីទី១ ត្រូវការថវិកាសរុប ១.១៥០.៥៧៦,២៦លានរៀល (ថវិការដ្ឋ ១ ១៤៨ ៧៨៤,៩០ លានរៀល និងថវិកាដៃគូ ១ ៧៩១,៣៦ លានរៀល)។ កម្មវិធីទី២ ត្រូវការថវិកាសរុប ៦៣៥ ៦៤០,១៧ លានរៀល (ថវិការដ្ឋ ៥៣ ២០០,១៧ លានរៀលនិងថវិកាដៃគូ ៥៨២.៤៤០ លានរៀល)។ កម្មវិធីទី៣ ត្រូវការថវិកាសរុប ១៤ ៧៣៨,២០ លានរៀល (ថវិការដ្ឋ ១២ ៩៤១ លានរៀល និង ថវិកាដៃគូ ១ ៧៩៧,២០ លានរៀល) និងកម្មវិធីទី៤ ត្រូវការថវិកាសរុបចំនួន ១៦៧ ៣២៦,៨០ លានរៀល។

## ៥. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ មានសារៈសំខាន់ណាស់សម្រាប់កំណត់អំពីចំណូល-ចំណាយ តាមកម្មវិធីរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ឯកសារផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ បានបង្ហាញអំពីគោលដៅលទ្ធផលចុងក្រោយ និងលទ្ធផលក្នុងឆ្នាំ តាមកម្មវិធី និងអនុកម្មវិធី ដើម្បីចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងអភិវឌ្ឍន៍ជនបទ រួមជាមួយអង្គភាពក្រោមឱវាទ ដោយសហប្រតិបត្តិការជាមួយគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជនបានអនុវត្តដោយប្រសិទ្ធភាពនូវតួនាទី និងភារកិច្ចរបស់ខ្លួន ដើម្បីបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋនៅជនបទទូទាំងប្រទេស រួមមាន ការស្ថាបនា និងការលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្តគមនាគមន៍ សម្រាប់សាធារណៈជន រួមមានការស្ថាបនាផ្លូវថ្មី ការងារជួសជុលថែទាំ និងកែលម្អផ្លូវជនបទ ពីផ្លូវក្រាលក្រួសក្រហមមកជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង សាងសង់ស្ពានបេតុង សំណង់សិល្បការគ្រប់ប្រភេទ រៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវជនបទនៅទូទាំងប្រទេស ដាក់ស្លាកសញ្ញាចរាចរណ៍លើផ្លូវជនបទ ដែលបានកសាងរួច។ សាងសង់ និងជួសជុលប្រព័ន្ធធារាសាស្ត្រខ្នាតតូច ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដល់គ្រប់ច្រកល្ហកតាមតំបន់ជនបទ។ អប់រំសុខភាព អនាម័យឲ្យប្រជាពលរដ្ឋរស់នៅស្អាត បង្កើនលក្ខខណ្ឌរស់នៅឲ្យបានល្អប្រសើរ។ ការបង្កើតការងារ មុខរបរ និងសកម្មភាពសេដ្ឋកិច្ចនៅតាមជនបទ ដើម្បីបង្កើនប្រាក់ចំណូលតាមគ្រួសារ។ ការអភិវឌ្ឍសហគមន៍ តាមរយៈការបង្កើត និងបណ្តុះបណ្តាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) អំពីវិធីសាស្ត្រកសាងផែនការអភិវឌ្ឍន៍ភូមិ ណែនាំដល់ប្រជាពលរដ្ឋឲ្យចេះចិញ្ចឹមសត្វ ចិញ្ចឹមត្រី ផលិតកម្មកសិកម្មជាលក្ខណៈគ្រួសារ ពន្យល់ណែនាំដល់ប្រជាពលរដ្ឋឲ្យយល់ដឹងពីការការពារគ្រោះភ័យក្នុងសហគមន៍ ដែលបណ្តាលមកពីកត្តាធម្មជាតិ។ ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទតាមរយៈការផ្តល់ឥណទានសាច់ប្រាក់ ឥណទានគោ មាន់ទា ធនាគារស្រូវ បណ្តុះបណ្តាលប្រជាពលរដ្ឋឲ្យមានជំនាញតម្បាញហូលក្រមា សារុងសូត្រ បណ្តុះបណ្តាលជំនាញចង្រ្កានឡជីវៈឧស្ម័ន ចង្រ្កានឡូវ ចង្រ្កាននាងកង្រី។ល។ មួយចំណែកទៀត ក្រសួងបានយកចិត្តទុកដាក់បើកវគ្គបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈ ដើម្បីបង្កើតការងារជូនប្រជាពលរដ្ឋ រួមមាន បង្រៀនជាងកាត់សក់ អ៊ុតសក់ កាត់ដេរ ជាងជួសជុលគ្រឿងម៉ាស៊ីន ម៉ូតូ រថយន្តគ្រឿងយន្តកសិកម្ម ជាងធ្វើសង្ហារឹម ជាងសំណង់ ជាងជួសជុលទូរស័ព្ទដៃ ជាងជួសជុលម៉ាស៊ីនដេរ បង្រៀនភាសាអង់គ្លេស និងកុំព្យូទ័រថ្នាក់មូលដ្ឋាន។ល។ ជាងនេះទៅទៀត មន្ត្រីជំនាញបានជួយណែនាំពីការផលិត និងស្វែងរកទីផ្សារលក់ផលិតផលជូនកសិករផងដែរ។ សកម្មភាពទាំងអស់ខាងលើសុទ្ធតែបានរួមចំណែកធ្វើឲ្យសេដ្ឋកិច្ចគ្រួសាររបស់ប្រជាពលរដ្ឋនៅជនបទឲ្យមានជីវភាពល្អប្រសើរឡើងជាលំដាប់ និងជួយជំរុញដល់ការអភិវឌ្ឍប្រទេសយ៉ាងឆាប់រហ័ស។

ទោះបីជាសម្រេចបាននូវសមិទ្ធផល និងការងារច្រើនយ៉ាងណាក៏ដោយ ក្រសួងអភិវឌ្ឍន៍ជនបទ នៅតែត្រូវការការគាំទ្រយ៉ាងខ្លាំងបន្ថែមទៀតពីរាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហា**

**សេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំប្រកបដោយភាពឆ្លាតវៃ និងប៉ិនប្រសប់ ព្រមទាំងមានការចូលរួមពីដៃគូអភិវឌ្ឍន៍នានា ទាំងបច្ចេកទេស និងធនធាន ពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឲ្យក្រសួងអភិវឌ្ឍន៍ជនបទ មានលទ្ធភាពក្នុងការស្ថាបនា និងស្តារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទាំងឡាយសម្រាប់បម្រើតម្រូវការ និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានបានទាន់ពេលវេលា។

**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**

# ខេ្ម អឹក្ក័លកន

| ល.រ. | ឈ្មោះក្រសួង ស្ថាប័ន/ឈ្មោះគម្រោង | លេខ PIP | តម្លៃគម្រោង | ចំណាយរហូតដល់ ២០២១ | ចំណាយប៉ាន់ស្មាន | | | | ហិរញ្ញប្បទានដែលសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ២០២៣ | ២០២៤ | ២០២៥ | សរុប ២០២៣-២០២៥ | ប្រភពទុន | ២០២៣ | ២០២៤ | ២០២៥ | សរុប ២០២៣-២០២៥ | ២០២៣ | ២០២៤ | ២០២៥ | សរុប ២០២៣-២០២៥ |
| | **គម្រោងកំពុងដំណើរការ** | | | | | | | | | | | | | | | | |
| | **គម្រោងវិនិយោគជាទុន** | | | | | | | | | | | | | | | | |
| | ១- សាច់ប្រាក់ពលកម្មដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ | 700 | 27,361.8 | 0.0 | 2,136.2 | 0.0 | 0.0 | 2,136.2 | RGC | 2,136.2 | 0.0 | 0.0 | 2,136.2 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | | Total | 2,136.2 | 0.0 | 0.0 | 2,136.2 | | | | |
| | ២- គម្រោងកែលម្អផ្លូវជនបទ ដំណាក់៣ | 995 | 133,574.0 | 25,637.0 | 69,863.0 | 7,195.0 | 8,662.0 | 85,720.0 | RGC | 3,793.0 | 4,000.0 | 739.0 | 8,532.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | | Republic of Korea | 33,070.0 | 1,847.0 | 6,785.0 | 41,702.0 | | | | |
| | | | | | | | | | ADB | 33,000.0 | 1,348.0 | 1,138.0 | 35,486.0 | | | | |
| | | | | | | | | | Total | 69,863.0 | 7,195.0 | 8,662.0 | 85,720.0 | | | | |
| | ៣- ពិពិធកម្មកសិកម្មកម្ពុជា ( សមាសភាគទី២ ឧបសម្ព័ន្ធ ២.២ គាំទ្រការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ) | 1032 | 25,000.0 | 156.2 | 9,598.2 | 9,598.2 | 4,598.2 | 23,794.6 | RGC | 1,800.0 | 1,800.0 | 1,000.0 | 4,600.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | | World Bank | 7,798.2 | 7,798.2 | 3,598.2 | 19,194.6 | | | | |
| | | | | | | | | | Total | 9,598.2 | 9,598.2 | 4,598.2 | 23,794.6 | | | | |
| | ៤- គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម | 1021 | 22,000.0 | 60.0 | 11,000.0 | 11,000.0 | 0.0 | 22,000.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | | AfD | 11,000.0 | 11,000.0 | 0.0 | 22,000.0 | | | | |
| | | | | | | | | | Total | 11,000.0 | 11,000.0 | 0.0 | 22,000.0 | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៥- គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ | 1020 | 62,500.0 | 0.0 | 18,025.7 | 0.0 | 0.0 | 18,025.7 | RGC | 58.4 | 0.0 | 0.0 | 58.4 | 674.9 | 0.0 | 0.0 | 674.9 |
| | | | | | | | | World Bank | 17,292.4 | 0.0 | 0.0 | 17,292.4 | | | | |
| | | | | | | | | Total | 17,350.8 | 0.0 | 0.0 | 17,350.8 | | | | |
| ៦- គម្រោងគាំទ្រនិរន្តរភាពហេដ្ឋារចនាសម្ព័ន្ធដើម្បីទីផ្សារកសិករ និងពាណិជ្ជូបនីយកម្មកសិកម្ម | 1019 | 157,185.0 | 0.0 | 7,428.8 | 5,335.3 | 5,076.0 | 17,840.1 | | | | | | 7,376.0 | 5,276.0 | 5,076.0 | 17,728.0 |
| | | | | | | | | IFAD | 52.8 | 59.3 | 0.0 | 112.1 | | | | |
| | | | | | | | | Total | 52.8 | 59.3 | 0.0 | 112.1 | | | | |
| ៧- គម្រោងផ្លូវជនបទកម្ពុជា ក្រោមហិរញ្ញប្បទានពីសាធារណៈរដ្ឋប្រជាមានិតចិន | 1018 | 44,572.7 | 0.0 | 14,857.6 | 14,857.6 | 0.0 | 29,715.2 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | China | 14,857.6 | 14,857.6 | 0.0 | 29,715.2 | | | | |
| | | | | | | | | Total | 14,857.6 | 14,857.6 | 0.0 | 29,715.2 | | | | |
| ៨- គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទដែលធន់នឹងការប្រែប្រួលអាកាសធាតុ | 1104 | 63,061.0 | 583.0 | 6,887.9 | 9,832.0 | 42,436.1 | 59,156.0 | RGC | 2,018.0 | 2,018.0 | 2,019.0 | 6,055.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | Korea | 4,869.9 | 7,814.0 | 40,417.1 | 53,101.0 | | | | |
| | | | | | | | | Total | 6,887.9 | 9,832.0 | 42,436.1 | 59,156.0 | | | | |
| ៩- គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា | 1281 | 25,062.0 | 0.0 | 48.8 | 48.8 | 0.0 | 97.6 | RGC | 48.8 | 48.8 | 0.0 | 97.6 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | Total | 48.8 | 48.8 | 0.0 | 97.6 | | | | |
| ១០- គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន | 1180 | 37,350.0 | 51.5 | 19,855.0 | 9,363.8 | 201.0 | 29,419.8 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | ADB | 19,855.0 | 9,363.8 | 201.0 | 29,419.8 | | | | |
| | | | | | | | | Total | 19,855.0 | 9,363.8 | 201.0 | 29,419.8 | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១១- គម្រោងកែលម្អការតភ្ជាប់ផ្លូវថ្នល់ | 1288 | 50,000.0 | 0.0 | 15,000.0 | 0.0 | 0.0 | 15,000.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | World Bank | 15,000.0 | 0.0 | 0.0 | 15,000.0 | | | | |
| | | | | | | | | Total | 15,000.0 | 0.0 | 0.0 | 15,000.0 | | | | |
| ១២- កម្មវិធីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទនៅកម្ពុជា | 1290 | 115,927.0 | 0.0 | 18,080.0 | 18,080.0 | 0.0 | 36,160.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | AfD | 11,300.0 | 11,300.0 | 0.0 | 22,600.0 | | | | |
| | | | | | | | | KFW | 6,780.0 | 6,780.0 | 0.0 | 13,560.0 | | | | |
| | | | | | | | | Total | 18,080.0 | 18,080.0 | 0.0 | 36,160.0 | | | | |
| ១៣- គម្រោងពង្រីកសមត្ថភាពផលិតភាពជនបទ | 1308 | 67,500.0 | 150.0 | 45,300.0 | 22,200.0 | 0.0 | 67,500.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | AIIB | 45,300.0 | 22,200.0 | 0.0 | 67,500.0 | | | | |
| | | | | | | | | Total | 45,300.0 | 22,200.0 | 0.0 | 67,500.0 | | | | |
| ១៤- គម្រោងកែលម្អបណ្តាញតភ្ជាប់ជនបទប្រកបដោយចីរភាព | 1319 | 67,788.0 | 0.0 | 16,104.0 | 16,006.0 | 16,644.0 | 48,754.0 | RGC | 1,960.0 | 1,960.0 | 1,959.0 | 5,879.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | Republic of Korea | 14,144.0 | 14,046.0 | 14,685.0 | 42,875.0 | | | | |
| | | | | | | | | Total | 16,104.0 | 16,006.0 | 16,644.0 | 48,754.0 | | | | |
| ១៥- ការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) | 1047 | 405.0 | 0.0 | 130.0 | 135.0 | 140.0 | 405.0 | RGC | 130.0 | 135.0 | 140.0 | 405.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | Total | 130.0 | 135.0 | 140.0 | 405.0 | | | | |
| ១៦- ការអភិវឌ្ឍភូមិចម្រុះ | 1048 | 195.0 | 0.0 | 60.0 | 65.0 | 70.0 | 195.0 | RGC | 60.0 | 65.0 | 70.0 | 195.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | Total | 60.0 | 65.0 | 70.0 | 195.0 | | | | |
| ១៧- លើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ | 1050 | 150.0 | 0.0 | 45.0 | 50.0 | 55.0 | 150.0 | RGC | 45.0 | 50.0 | 55.0 | 150.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | Total | 45.0 | 50.0 | 55.0 | 150.0 | | | | |
| ១៨- ពង្រឹងសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ | 1051 | 240.0 | 0.0 | 75.0 | 80.0 | 85.0 | 240.0 | RGC | 75.0 | 80.0 | 85.0 | 240.0 | 0.0 | 0.0 | 0.0 | 0.0 |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Total | 75.0 | 80.0 | 85.0 | 240.0 | | | | |
| ១៩- ពង្រឹងសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ | 1033 | 1,455.0 | 0.0 | 480.0 | 485.0 | 490.0 | 1,455.0 | RGC | 80.0 | 85.0 | 90.0 | 255.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | KOICA | 400.0 | 400.0 | 400.0 | 1,200.0 | | | | |
| | | | | | | | | Total | 480.0 | 485.0 | 490.0 | 1,455.0 | | | | |
| ២០- បញ្ជ្រាបការយល់ដឹងពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយក្នុងសហគមន៍ | 1049 | 90.0 | 0.0 | 25.0 | 30.0 | 35.0 | 90.0 | RGC | 25.0 | 30.0 | 35.0 | 90.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | Total | 25.0 | 30.0 | 35.0 | 90.0 | | | | |
| ២១- គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទ ដំណាក់ទី៣ | 1313 | 10,000.0 | 0.0 | 10,000.0 | 0.0 | 0.0 | 10,000.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | ADB | 10,000.0 | 0.0 | 0.0 | 10,000.0 | | | | |
| | | | | | | | | Total | 10,000.0 | 0.0 | 0.0 | 10,000.0 | | | | |
| ២២- គម្រោងផ្គត់ផ្គង់ទឹកស្អាតជនបទនិងអនាម័យ ដំណាក់ទី៣ | 1038 | 35,000.0 | 0.0 | 8,014.6 | 2,770.0 | 0.0 | 10,784.6 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | ADB | 8,014.6 | 2,770.0 | 0.0 | 10,784.6 | | | | |
| | | | | | | | | Total | 8,014.6 | 2,770.0 | 0.0 | 10,784.6 | | | | |
| ២៣- គម្រោងផ្គត់ផ្គង់ទឹកជនបទកម្ពុជា ដំណាក់ទី២ | 1027 | 6,000.0 | 0.0 | 0.0 | 6,000.0 | 0.0 | 6,000.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | China | 0.0 | 6,000.0 | 0.0 | 6,000.0 | | | | |
| | | | | | | | | Total | 0.0 | 6,000.0 | 0.0 | 6,000.0 | | | | |
| ២៤- គម្រោងបំពេញបន្ថែមលើគម្រោងសហប្រតិបត្តិការសាកល្បងកាត់បន្ថយភាពក្រីក្រកម្ពុជា-ចិន នៅស្រុកមុខកំពូល ខេត្តកណ្តាល | 1316 | 465.0 | 0.0 | 465.0 | 0.0 | 0.0 | 465.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | China | 465.0 | 0.0 | 0.0 | 465.0 | | | | |
| | | | | | | | | Total | 465.0 | 0.0 | 0.0 | 465.0 | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២៥- គម្រោងចែកចាយទឹកស្អាត ដើម្បីអនាគតទាំងអស់គ្នា ក្នុងខេត្តតាកែវ ប្រទេសកម្ពុជា | 1318 | 453.0 | 0.0 | 453.0 | 0.0 | 0.0 | 453.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | China | 453.0 | 0.0 | 0.0 | 453.0 | | | | |
| | | | | | | | | Total | 453.0 | 0.0 | 0.0 | 453.0 | | | | |
| ២៦- គម្រោងពិពិធកម្មសេដ្ឋកិច្ចជនបទ សម្រាប់កសិករដែលមានចំណូលទាប ក្នុងស្រុកគិរីវង់ ខេត្តតាកែវ ប្រទេសកម្ពុជា | 1317 | 420.0 | 0.0 | 420.0 | 0.0 | 0.0 | 420.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | China | 420.0 | 0.0 | 0.0 | 420.0 | | | | |
| | | | | | | | | Total | 420.0 | 0.0 | 0.0 | 420.0 | | | | |
| សរុប គម្រោងវិនិយោគជាទុន | | | | | | | | RGC | 12,229.4 | 10,271.8 | 6,192.0 | 28,693.2 | | | | |
| | | | | | | | | DPs | 254,072.5 | 117,583.9 | 67,224.3 | 438,880.7 | | | | |
| | | 953,754.5 | 26,637.7 | 274,352.8 | 133,131.7 | 78,492.3 | 485,976.8 | សរុប | 266,301.9 | 127,855.7 | 73,416.3 | 467,573.9 | 8,050.9 | 5,276.0 | 5,076.0 | 18,402.9 |
| គម្រោងជំនួយបច្ចេកទេស | | | | | | | | | | | | | | | | |
| ១- ប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់វិស័យទឹកស្អាតនិងអនាម័យ | 818 | 230.9 | 0.0 | 89.9 | 0.0 | 0.0 | 89.9 | | | | | | 17.5 | 0.0 | 0.0 | 17.5 |
| | | | | | | | | Other | 31.1 | 0.0 | 0.0 | 31.1 | | | | |
| | | | | | | | | UNICEF | 29.9 | 0.0 | 0.0 | 29.9 | | | | |
| | | | | | | | | CCCA | 11.4 | 0.0 | 0.0 | 11.4 | | | | |
| | | | | | | | | Total | 72.4 | 0.0 | 0.0 | 72.4 | | | | |
| សរុប គម្រោងជំនួយបច្ចេកទេស | | | | | | | | RGC | 0.0 | 0.0 | 0.0 | 0.0 | | | | |
| | | | | | | | | DPs | 72.4 | 0.0 | 0.0 | 72.4 | | | | |
| | | 230.9 | 0.0 | 89.9 | 0.0 | 0.0 | 89.9 | សរុប | 72.4 | 0.0 | 0.0 | 72.4 | 17.5 | 0.0 | 0.0 | 17.5 |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សរុប គម្រោងកំពុងដំណើរការ | | | | | | | | RGC | 12,229.4 | 10,271.8 | 6,192.0 | 28,693.2 | | | | |
| | | | | | | | | DPs | 254,144.9 | 117,583.9 | 67,224.3 | 438,953.1 | | | | |
| | | 953,985.4 | 26,637.7 | 274,442.7 | 133,131.7 | 78,492.3 | 486,066.7 | សរុប | 266,374.3 | 127,855.7 | 73,416.3 | 467,646.3 | 8,068.4 | 5,276.0 | 5,076.0 | 18,420.4 |
| គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. | | | | | | | | | | | | | | | | |
| គម្រោងវិនិយោគជាទុន | | | | | | | | | | | | | | | | |
| ១- អភិវឌ្ឍន៍បម្រុះសហគមន៍ជនជាតិដើមភាគតិច | 607 | 170.0 | 0.0 | 17.0 | 86.0 | 67.0 | 170.0 | | | | | | 17.0 | 86.0 | 67.0 | 170.0 |
| ២- គម្រោងផ្គត់ផ្គង់ទឹកស្អាតជនបទទូទាំង២៥ រាជធានី ខេត្ត | 1030 | 70,000.0 | 0.0 | 1,200.0 | 1,600.0 | 1,200.0 | 4,000.0 | | | | | | 1,200.0 | 1,600.0 | 1,200.0 | 4,000.0 |
| ៣- ការស្តារ/ការជួសជុល និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជនបទ | 1025 | 191,000.0 | 0.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | | | | | | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 |
| ៤- ការកែលម្អផ្លូវពីកម្រាលក្រួសក្រហមទៅជាកៅស៊ូពីរជាន់ និងកម្រាលផ្សេងទៀត (ដំហានទី១) | 1024 | 117,000.0 | 0.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | | | | | | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 |
| ៥- ការអភិវឌ្ឍជនបទដោយផ្តោតលើការបង្កើនប្រាក់ចំណូលរបស់កសិករកម្ពុជា | 1023 | 10,000.0 | 0.0 | 3,000.0 | 4,000.0 | 3,000.0 | 10,000.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | Republic of Korea | 3,000.0 | 4,000.0 | 3,000.0 | 10,000.0 | | | | |
| | | | | | | | | Total | 3,000.0 | 4,000.0 | 3,000.0 | 10,000.0 | | | | |
| ៦- ការអភិវឌ្ឍសហគមន៍ជនបទ និងការលើកកម្ពស់កសិ-អាជីវកម្មនៅក្នុងប្រទេសកម្ពុជា | 1022 | 5,000.0 | 0.0 | 1,500.0 | 2,000.0 | 1,500.0 | 5,000.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | Republic of Korea | 1,500.0 | 2,000.0 | 1,500.0 | 5,000.0 | | | | |
| | | | | | | | | Total | 1,500.0 | 2,000.0 | 1,500.0 | 5,000.0 | | | | |
| ៧- គម្រោងផ្គត់ផ្គង់ទឹកស្អាតជនបទទូទាំង២៥ រាជធានី ខេត្ត | 1161 | 53,600.0 | 0.0 | 1,200.0 | 1,700.0 | 1,700.0 | 4,600.0 | | | | | | 1,200.0 | 1,700.0 | 1,700.0 | 4,600.0 |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៨- ការកសាងសន្តិភាព និងភាពរុងរឿងក្នុងភូមិ តាមរយៈការអភិវឌ្ឍសហគមន៍ចម្រុះ | 1163 | 10,000.0 | 0.0 | 4,000.0 | 3,000.0 | 3,000.0 | 10,000.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | Korea | 4,000.0 | 3,000.0 | 3,000.0 | 10,000.0 | | | | |
| | | | | | | | | Total | 4,000.0 | 3,000.0 | 3,000.0 | 10,000.0 | | | | |
| ៩- ការកែលម្អផ្លូវពីកម្រាលក្រួសទៅជាកៅស៊ូពីរជាន់និងកម្រាលផ្សេងៗ (ជំហានទី២) | 1164 | 63,750.0 | 0.0 | 1,160.0 | 1,160.0 | 1,160.0 | 3,480.0 | | | | | | 1,160.0 | 1,160.0 | 1,160.0 | 3,480.0 |
| ១០- គម្រោងអភិវឌ្ឍបណ្តាញផ្លូវជនបទ | 1289 | 60,000.0 | 0.0 | 2,000.0 | 3,000.0 | 15,000.0 | 20,000.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | Korea | 2,000.0 | 3,000.0 | 15,000.0 | 20,000.0 | | | | |
| | | | | | | | | Total | 2,000.0 | 3,000.0 | 15,000.0 | 20,000.0 | | | | |
| ១១- គម្រោងកែលម្អការតភ្ជាប់ផ្លូវជនបទធន់នឹងការប្រែប្រួលអាកាសធាតុ | 1315 | 100,000.0 | 0.0 | 33,030.0 | 33,030.0 | 33,940.0 | 100,000.0 | RGC | 3,030.0 | 3,030.0 | 3,030.0 | 9,090.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | JICA | 30,000.0 | 30,000.0 | 30,910.0 | 90,910.0 | | | | |
| | | | | | | | | Total | 33,030.0 | 33,030.0 | 33,940.0 | 100,000.0 | | | | |
| ១២- គម្រោងកែលម្អការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ជំហានទី II | 1325 | 70,000.0 | 0.0 | 22,270.0 | 21,960.0 | 29,900.0 | 74,130.0 | RGC | 2,270.0 | 1,960.0 | 50.0 | 4,280.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | World Bank | 20,000.0 | 20,000.0 | 29,850.0 | 69,850.0 | | | | |
| | | | | | | | | Total | 22,270.0 | 21,960.0 | 29,900.0 | 74,130.0 | | | | |
| ១៣- គម្រោងផ្គត់ផ្គង់ទឹកស្អាតជនបទទូទាំង ២៥ រាជធានី ខេត្ត | 1311 | 63,450.0 | 0.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | | | | | | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 |
| ១៤- គម្រោងកែលម្អបណ្តាញតភ្ជាប់ជនបទប្រកបដោយចីរភាព ជំហានទី២ | 1323 | 67,788.0 | 0.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | | | | | | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 |
| ១៥- គម្រោងកែលម្អផ្លូវជនបទ ជំហាន៤ | 1321 | 66,000.0 | 0.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | | | | | | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 |
| ១៦- គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទដែលធន់នឹងការប្រែប្រួលអាកាសធាតុជំហានទី២ | 1322 | 66,000.0 | 0.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | | | | | | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៧- គម្រោងអភិវឌ្ឍបណ្ដាញផ្លូវជនបទ | 1324 | 66,000.0 | 0.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | | | | | | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 |
| ១៨- គម្រោងកែលម្អបណ្ដាញតភ្ជាប់ជនបទភូមិភាគឦសាន | 1320 | 66,000.0 | 0.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | | | | | | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 |
| ១៩- ការគាំទ្រជំនាញជាមូលដ្ឋាន និងការបង្កើតការងារ | 239 | 500.0 | 0.0 | 170.0 | 170.0 | 160.0 | 500.0 | | | | | | 170.0 | 170.0 | 160.0 | 500.0 |
| ២០- គម្រោងឥណទានសហគមន៍សន្សំប្រាក់ | 240 | 2,000.0 | 0.0 | 1,600.0 | 200.0 | 200.0 | 2,000.0 | | | | | | 1,600.0 | 200.0 | 200.0 | 2,000.0 |
| ២១- ការបង្កើនប្រាក់ចំណូលតាមរយៈកម្មវិធីអភិវឌ្ឍន៍សហគ្រិនភាពជនបទ | 244 | 3,000.0 | 0.0 | 850.0 | 1,350.0 | 800.0 | 3,000.0 | | | | | | 850.0 | 1,350.0 | 800.0 | 3,000.0 |
| ២២- គម្រោងគាំទ្រការងារឥណទានជនបទ | 218 | 2,360.0 | 0.0 | 1,818.8 | 260.8 | 280.4 | 2,360.0 | RGC | 1,818.8 | 260.8 | 280.4 | 2,360.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | Total | 1,818.8 | 260.8 | 280.4 | 2,360.0 | | | | |
| ២៣- គម្រោងសាងសង់ ស្ពា និងជួសជុលប្រព័ន្ធស្រោចស្រពខ្នាតតូច | 1160 | 21,780.0 | 0.0 | 1,380.0 | 1,200.0 | 1,200.0 | 3,780.0 | | | | | | 1,380.0 | 1,200.0 | 1,200.0 | 3,780.0 |
| ២៤- គម្រោងសាងសង់ ស្ពា និងជួសជុលប្រព័ន្ធស្រោចស្រពខ្នាតតូច | 1312 | 17,450.0 | 0.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | | | | | | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 |
| ២៥- ផ្ដល់មុខជំនាញជាមូលដ្ឋានលើការផលិតចង្រ្កានជីវម៉ាសសម្រាប់ភូមិគ្មានផ្សែង | 211 | 2,150.0 | 0.0 | 530.0 | 960.0 | 660.0 | 2,150.0 | | | | | | 530.0 | 960.0 | 660.0 | 2,150.0 |
| ២៦- ការលើកកម្ពស់សេដ្ឋកិច្ចជនបទតាមរយៈការជំរុញទីផ្សារផលិតផលជនបទ | 246 | 5,000.0 | 0.0 | 1,270.0 | 1,770.0 | 1,960.0 | 5,000.0 | | | | | | 1,270.0 | 1,770.0 | 1,960.0 | 5,000.0 |
| ២៧- លើកកម្ពស់ការផ្ដល់សេវាអនាម័យជនបទ | 195 | 6,450.0 | 0.0 | 1,150.0 | 1,150.0 | 1,150.0 | 3,450.0 | | | | | | 1,150.0 | 1,150.0 | 1,150.0 | 3,450.0 |
| ២៨- កសាងមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច | 200 | 1,929.0 | 0.0 | 650.0 | 929.0 | 350.0 | 1,929.0 | | | | | | 650.0 | 929.0 | 350.0 | 1,929.0 |
| ២៩- គម្រោងផ្គត់ផ្គង់ទឹកជនបទក្នុងប្រទេសកម្ពុជា | 1159 | 49,000.0 | 0.0 | 13,000.0 | 21,000.0 | 15,000.0 | 49,000.0 | | | | | | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | China | 13,000.0 | 21,000.0 | 15,000.0 | 49,000.0 | | | | |
| | | | | | | | | Total | 13,000.0 | 21,000.0 | 15,000.0 | 49,000.0 | | | | |
| ៣០- គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទ ដំណាក់កាលទីពីរ | 1162 | 17,720.0 | 0.0 | 1,720.0 | 1,000.0 | 1,000.0 | 3,720.0 | | | | | | 1,720.0 | 1,000.0 | 1,000.0 | 3,720.0 |
| ៣១- មជ្ឈមណ្ឌលបណ្ដុះបណ្ដាលជំនាញមូលដ្ឋាន | 152 | 900.0 | 0.0 | 500.0 | 200.0 | 200.0 | 900.0 | | | | | | 500.0 | 200.0 | 200.0 | 900.0 |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣២- ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងគ្រួសារ | 220 | 1,892.3 | 0.0 | 630.5 | 630.5 | 631.3 | 1,892.3 | | | | | | 630.5 | 630.5 | 631.3 | 1,892.3 |
| សរុប គម្រោងវិនិយោគជាទុន | | | | | | | | RGC | 7,118.8 | 5,250.8 | 3,360.4 | 15,730.0 | | | | |
| | | | | | | | | DPs | 73,500.0 | 83,000.0 | 98,260.0 | 254,760.0 | | | | |
| | | 1,277,889.3 | 0.0 | 103,646.3 | 111,356.3 | 123,058.7 | 338,061.3 | សរុប | 80,618.8 | 88,250.8 | 101,620.4 | 270,490.0 | 23,027.5 | 23,105.5 | 21,438.3 | 67,571.3 |
| គម្រោងជំនួយបច្ចេកទេស | | | | | | | | | | | | | | | | |
| ១- ការពង្រឹងការងារគ្រប់គ្រងរដ្ឋបាល និងបុគ្គលិក | 1036 | 900.0 | 0.0 | 300.0 | 300.0 | 300.0 | 900.0 | | | | | | 300.0 | 300.0 | 300.0 | 900.0 |
| ២- គាំទ្រកិច្ចសវនកម្មផ្ទៃក្នុង | 1314 | 180.0 | 0.0 | 65.0 | 60.0 | 55.0 | 180.0 | | | | | | 65.0 | 60.0 | 55.0 | 180.0 |
| ៣- ពង្រឹងកិច្ចសវនកម្មផ្ទៃក្នុង | 87 | 180.0 | 0.0 | 60.0 | 60.0 | 60.0 | 180.0 | | | | | | 60.0 | 60.0 | 60.0 | 180.0 |
| ៤- ការអភិវឌ្ឍធនធានមនុស្ស | 149 | 2,100.0 | 0.0 | 700.0 | 700.0 | 700.0 | 2,100.0 | | | | | | 700.0 | 700.0 | 700.0 | 2,100.0 |
| ៥- ជំនាញវាយតម្លៃ និងស្រាវជ្រាវ | 158 | 514.0 | 0.0 | 171.0 | 171.0 | 172.0 | 514.0 | | | | | | 171.0 | 171.0 | 172.0 | 514.0 |
| សរុប គម្រោងជំនួយបច្ចេកទេស | | | | | | | | RGC | 0.0 | 0.0 | 0.0 | 0.0 | | | | |
| | | | | | | | | DPs | 0.0 | 0.0 | 0.0 | 0.0 | | | | |
| | | 3,874.0 | 0.0 | 1,296.0 | 1,291.0 | 1,287.0 | 3,874.0 | សរុប | 0.0 | 0.0 | 0.0 | 0.0 | 1,296.0 | 1,291.0 | 1,287.0 | 3,874.0 |
| សរុប គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. | | | | | | | | RGC | 7,118.8 | 5,250.8 | 3,360.4 | 15,730.0 | | | | |
| | | | | | | | | DPs | 73,500.0 | 83,000.0 | 98,260.0 | 254,760.0 | | | | |
| | | 1,281,763.3 | 0.0 | 104,942.3 | 112,647.3 | 124,345.7 | 341,935.3 | សរុប | 80,618.8 | 88,250.8 | 101,620.4 | 270,490.0 | 24,323.5 | 24,396.5 | 22,725.3 | 71,445.3 |
| សរុប ក្រសួងអភិវឌ្ឍន៍ជនបទ | | | | | | | | RGC | 19,348.2 | 15,522.6 | 9,552.4 | 44,423.2 | | | | |
| | | | | | | | | DPs | 327,644.9 | 200,583.9 | 165,484.3 | 693,713.1 | | | | |
| | | 2,235,748.7 | 26,637.7 | 379,385.0 | 245,779.0 | 202,838.0 | 828,002.0 | សរុប | 346,993.1 | 216,106.5 | 175,036.7 | 738,136.3 | 32,391.9 | 29,672.5 | 27,801.3 | 89,865.7 |

ពជូ ឱក្តឺលឃឆខ

## គម្រោងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍

| ល.រ | ឈ្មោះគម្រោង<br>Project Name | សមាសភាពគម្រោង<br>Project Component | ប្រភពថវិកា<br>Source | រយៈពេលអនុវត្តគម្រោង<br>Project Period | អ្នកពាក់ព័ន្ធ និងអ្នកទទួលខុសត្រូវ<br>Stakeholder | ទីតាំងអនុវត្តគម្រោង |
|---|---|---|---|---|---|---|
| 1 | គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ | 1. ផ្លូវធន់នឹងការប្រែប្រួលអាកាសធាតុ<br>2.ពង្រឹងការធ្វើផែនការហិរញ្ញវត្ថុសម្រាប់គ្រោះមហន្តរាយ<br>3. ការគ្រប់គ្រងគម្រោង<br>4. ការឆ្លើយតមនឹងគ្រោះបន្ទាន់ | ធនាគារពិភពលោក និងរដ្ឋាភិបាល | ៥ ឆ្នាំ ចាប់ពី ០១ មករា ២០២១ ដល់ ៣១ មីនា ២០២២ | ឯកឧត្តម ជ្រោយ ប៉ុម នាយគម្រោង<br>ក្រសួងអភិវឌ្ឍន៍ជនបទ<br>ធនាគារពិភពលោក<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមហ៊ុនទីប្រឹក្សា KCI | ខេត្តត្បូងឃ្មុំ,ក្រចេះ,សៀមរាប, ស្ទឹងត្រែង,កំពង់ចាម,កណ្ដាល |
| 2 | គម្រោងកែលម្អផ្លូវជនបទជំហានទី ២<br>( RRIP-II ) | 1. កែលម្អផ្លូវជនបទក្នុងខេត្តគោលដៅចំនួន ១០ ខេត្ត<br>2. គ្រប់គ្រងសម្បត្តិផ្លូវជនបទ<br>3. សុវត្ថិភាពចរាចរណ៍ផ្លូវជនបទ និងបង្កើនចំណេះដឹងដល់សហគមន៍<br>4. គាំទ្រការងារគ្រប់គ្រងគម្រោង<br>5. កែលម្អបណ្តាញតភ្ជាប់បណ្តាកោះនៃដងទន្លេមេគង្គ | ADB, AFD, KEXIM Bank, DFAT, GOA, NDF និង RGC | ចាប់ពី ២៣ ធ្នូ ២០១៤ ដល់ ៣១ ធ្នូ ២០២០ | ឯកឧត្តមបណ្ឌិត ចាន់ ដារុង អ្នកសម្របសម្រួលគម្រោង<br>ក្រសួងអភិវឌ្ឍន៍ជនបទ ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអាហារ៉ែណ នីហារ៉ែណកូរ៉េ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស ( PEC, KCI, PEC, Sheladia, SOFRECO, SBK ) | ខេត្តកំពង់ស្ពឺ,ត្បូងឃ្មុំ,បន្ទាយមានជ័យ,កំពង់ធំ,សៀមរាប.បាត់ដំបង, កំពង់ចាម,កំពង់ឆ្នាំង,ពោធិ៍សាត់, តាកែវ |
| 3 | គម្រោងកែលម្អផ្លូវជនបទជំហានទី ៣<br>( RRIP-III ) | 1. កែលម្អផ្លូវជនបទក្នុងខេត្តគោលដៅចំនួន ១០ ខេត្ត<br>2. ធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងសម្បត្តិផ្លូវជនបទ<br>3. ការលើកកំពស់ការយល់ដឹងអំពីសុវត្ថិភាពចរាចរណ៍ និងផលប៉ះពាល់ផ្សេងៗដល់សង្គម | ADB, KEXIM Bank | ចាប់ពី ២៩ សីហា ២០១៨ ដល់ ៣០ មិថុនា ២០២៦ | ឯកឧត្តមបណ្ឌិត ចាន់ ដារុង អ្នកសម្របសម្រួលគម្រោង<br>ក្រសួងអភិវឌ្ឍន៍ជនបទ ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអាហារ៉ែណ នីហារ៉ែណកូរ៉េ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រុមហ៊ុនទី ប្រឹក្សាបច្ចេកទេស (KCI) | ខេត្តកំពង់ស្ពឺ,ត្បូងឃ្មុំ,ក្រចេះ.កំពត, កំពង់ចាម,កណ្ដាល.ព្រៃវែង, ស្វាយរៀង,កំពង់ឆ្នាំង,តាកែវ |
